មេរៀនទី ២

# ព្រះជាម្ចាស់៖ លក្ខណសម្បត្តិខាងឯសីលធម៌ និង កិច្ចការរបស់ទ្រង់

ពេលខ្លះតើអ្នកឆ្ងល់ខ្លាំងណាស់មែនទេ នៅពេលអ្នកអានកាសែត ហើយឃើញមានសោកនាដកម្មដ៏អស្ចារ្យបានកើតលើជីវិតរបស់គ្រិស្តបរិស័ទ? តើអ្នកធ្លាប់ឃើញមនុស្សអាក្រក់ ទទួលបានការជោគជ័យ និង មានទ្រព្យសម្បត្តិយ៉ាងអស្ចារ្យតាមរយៈការធ្វើរឿងមិនស្មោះត្រង់ ហើយធ្លាប់គិតទេថា ហេតុអ្វីបានជាព្រះជាម្ចាស់អនុញ្ញាតឲ្យមានរឿងទាំងនេះកើតមានឡើង? ជារឿយៗ យើងអំពល់ចិត្តយ៉ាងខ្លាំង នៅពេលយើងឃើញពីអ្វីដែលហាក់ដូចជាមិនយុតិធម៌ ហើយយើងតែងតែទូលសួរទៅកាន់ព្រះជាម្ចាស់។

នៅពេលយើងយល់កាន់តែច្បាស់អំពីលក្ខណសម្បត្តិខាងឯសីលធម៌របស់ព្រះជាម្ចាស់ ដែលមានសេចក្តីស្រឡាញ់ និង ភាពបរិសុទ្ធរបស់ទ្រង់ ព្រមទាំងយល់ពីរបៀបដែលទ្រង់ធ្វើការនៅក្នុងលោកីយ៍សព្វថ្ងៃនេះ យើងនឹងឃើញថា អ្វីៗទាំងអស់ដែលកើតមានឡើងមកលើយើង គឺសុទ្ធតែមានគោលបំណងរបស់វា។ គោលដៅរបស់ព្រះជាម្ចាស់ គឺដើម្បីរៀបចំយើងសម្រាប់ព្រះរាជ្យដ៏អស់កល្បជានិច្ចរបស់ទ្រង់ ហើយទ្រង់ធ្វើសកម្មភាពនៅក្នុងជីវិតរបស់យើងសព្វថ្ងៃ គឺដើម្បីសម្រេចគោលដៅនោះ។

នៅក្នុងមេរៀននេះ យើងនឹងសិក្សាអំពីលក្ខណសម្បត្តិខាងឯសីលធម៌របស់ព្រះជាម្ចាស់ ហើយយើងនឹងឃើញថាព្រះជាម្ចាស់ដែលបានបង្កើតយើងរាល់គ្នា ទ្រង់ធ្វើការយ៉ាងសកម្មក្នុងការថែរក្សា ស្នាព្រះហស្តរបស់ទ្រង់ និង ប្រទានគ្រប់បែបយ៉ាងដែលត្រូវការ ដើម្បីនាំយើងឲ្យចូលទៅក្នុងព្រះរាជ្យរបស់ទ្រង់។ ទោះជាយ៉ាងណា ទ្រង់នៅតែអនុញ្ញាតឲ្យយើងធ្វើការសម្រេចចិត្តដោយខ្លួនឯង ហើយទទួលរ៉ាប់រងគ្រប់យ៉ាង ទៅលើការសម្រេចចិត្តរបស់យើង។ ចូរយើងបើកចិត្តរបស់យើងទៅកាន់ទ្រង់ ស្របពេលដែលយើងគិតពិចារណា នៅក្នុងការសិក្សាផ្នែកមួយនេះ ថាទ្រង់ស្រឡាញ់យើងដល់កម្រិតណា ព្រមទាំងពិចារណាអំពីរបៀបដែលទ្រង់គ្រប់គ្រងស្នាព្រះហស្តរបស់ទ្រង់ផងដែរ។

## គម្រោងមេរៀន

ក. លក្ខណសម្បត្តិខាងឯសីលធម៌របស់ព្រះជាម្ចាស់
ខ. រាជកិច្ចនៃការបង្កើតរបស់ព្រះជាម្ចាស់
គ. រាជកិច្ចនៃការគ្រងរាជ្យជាស្តេចរបស់ព្រះជាម្ចាស់

## វត្ថុបំណងមេរៀន

នៅពេលដែលអ្នកបញ្ចប់មេរៀននេះ អ្នកអាចនឹង៖

១. បកស្រាយពីសារៈសំខាន់នៃភាពបរិសុទ្ធរបស់ព្រះជាម្ចាស់។
២. ប្រាប់ថា និយមន័យនៃសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់សម្រាប់យើងជាអ្វី និង ប្រាប់ពីរបៀបដែលសេចក្តីស្រឡាញ់នោះស្តែងចេញមក។
៣. បកស្រាយសកម្មភាពនៃការបង្កើតរបស់ព្រះជាម្ចាស់ និង សារៈសំខាន់នៃការបង្កើតនោះសម្រាប់យើង។
៤. យកគោលការណ៍ទៅប្រើប្រាស់នៅក្នុងស្ថានភាពជីវិត និង ប្រាប់ពីនិយមន័យនៃការគ្រងរាជ្យជាស្តេចនៃសាកលលោករបស់ព្រះជាម្ចាស់។
៥. លើកឧទាហរណ៍អំពីគោលបំណង ធាតុមូលដ្ឋាន និង ឥទ្ធិពលនៃឧបការគុណរបស់ព្រះជាម្ចាស់។

## សកម្មភាពនៃការសិក្សា

១. សិក្សាតាមដំណើរវិវឌ្ឍរបស់មេរៀន ធ្វើតាមដំណើរការដូចនឹងមេរៀនទី១។ នៅពេលអ្នកឆ្លើយសំណួរក្នុងមេរៀន ត្រូវឲ្យប្រាកដថាអ្នកសរសេរចម្លើយរបស់អ្នក មុនពេលបើកមើលចម្លើយនៅចុងបញ្ចប់មេរៀន។
២. នៅពេលអ្នកបានបញ្ចប់មេរៀននេះ ចូរធ្វើការប្រឡងផ្ទាល់ខ្លួន ហើយផ្ទៀតផ្ទាត់ចម្លើយរបស់អ្នកដោយយកចិត្តទុកដាក់ ជាមួយនឹងចម្លើយដែលយើងបានផ្តល់ជូននៅផ្នែកខាងក្រោយនៃសៀវភៅសិក្សានេះ។ ចូររំឭកចំណុចណាដែលអ្នកចម្លើយមិនបានត្រឹមត្រូវ។

## ពាក្យសំខាន់

| | | |
|---|---|---|
| ការរំដោះបាប | អន្តរាគមន៍ | ការការពារ |
| ការសម្របសម្រួល | ភាពយុត្តិធម៌ | ឧបការគុណ (គុណូបការៈ) |
| ការយល់ស្រប | ការថែរក្សា | ភាពសុចរិត |
| បង្កើត | សេចក្តីមេត្តាករុណា | កំពូល |
| ឧត្តម | សីលធម៌ | ភាពទៀងត្រង់ |
| ភាពវិសុទ្ធ | | |

# ក. លក្ខណសម្បត្តិខាងឯសីលធម៌របស់ព្រះជាម្ចាស់

នៅក្នុងមេរៀនទី១ យើងបានសិក្សាអំពីលក្ខណសម្បត្តិនៃនិស្ស័យរបស់ព្រះជាម្ចាស់ និង គុណលក្ខណៈជាធម្មជាតិរបស់ទ្រង់។ ឥឡូវនេះយើងនឹងពិចារណាទៅលើ លក្ខណសម្បត្តិខាងឯ*សីលធម៌*របស់ព្រះជាម្ចាស់។ ទាំងនេះ គឺជាលក្ខណសម្បត្តិដែលព្រះជាម្ចាស់សម្ដែងឲ្យឃើញនៅពេលទ្រង់ ទាក់ទងជាមួយមនុស្ស។ លក្ខណៈទាំងនោះរួមមាន *ភាពវិសុទ្ធ*របស់ទ្រង់ និង*សេចក្ដីស្រឡាញ់*របស់ទ្រង់។ ដំបូងយើងនឹងមើលទៅលើ*ភាពវិសុទ្ធ*របស់ព្រះជាម្ចាស់។

## ភាពវិសុទ្ធរបស់ព្រះជាម្ចាស់

**វត្ថុបំណងទី១.** *បកស្រាយពីសារៈសំខាន់នៃភាពបរិសុទ្ធរបស់ព្រះជាម្ចាស់។*

តើអ្នកចង់ឲ្យអ្នកជិតខាងរបស់អ្នកស្គាល់អ្នកថាជាមនុស្សដែលមានលក្ខណៈយ៉ាងដូចម្ដេច? ជាមនុស្សកំណាញ់ម្នាក់? មនុស្សម្នាក់ដែលពូកែនិយាយដើមគេ? មនុស្សល្អម្នាក់? ជាមិត្តសម្លាញ់ម្នាក់? ព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យ ប្រជាជាតិនានាស្គាល់ទ្រង់ដោយលក្ខណៈពិសេសមួយ។ ទ្រង់សព្វព្រះហឫទ័យឲ្យគេហៅទ្រង់ថា *ព្រះដ៏វិសុទ្ធ។* (គម្ពីរអេសេគាល ៣៩:៧)។

យើងបានដឹងថា ព្រះជាម្ចាស់មិនអាចមានកំហុសខាងឯគំនិតបញ្ញាបាននោះទេ ព្រោះទ្រង់ជ្រាបគ្រប់ការទាំងអស់។ ដោយសារតែភាពវិសុទ្ធរបស់ទ្រង់ ទ្រង់មិនអាចមានកំហុសខាងឯសីលធម៌នោះទេ។ ភាពវិសុទ្ធគឺជាលក្ខណសម្បត្តិរបស់ព្រះជាម្ចាស់ដែលសម្ដែងពីភាពឥតខ្ចោះដែលជារបស់ទ្រង់។ ភាពវិសុទ្ធគឺជាមូលដ្ឋានគ្រឹះសម្រាប់សកម្មភាពទាំងអស់របស់ទ្រង់។ដូច្នេះ អ្វីៗគ្រប់យ៉ាងដែលទ្រង់ធ្វើ គឺត្រឹមត្រូវ និង ល្អ។

ពាក្យថា*ភាពវិសុទ្ធ* មានភ្ជាប់មកជាមួយគំនិតនៃ*ការបែងចែក* ។ ព្រះដ៏ល្អឥតខ្ចោះគឺត្រូវតែបែងចែកឲ្យដាច់ និង ឧដុង្គឧត្ដម (លើកឲ្យខ្ពស់ឡើង) លើសផុតមនុស្សមានបាប និង ការអាក្រក់។ ប៉ុន្តែ ទោះបីទ្រង់វិសុទ្ធឥតខ្ចោះ និង បែងចែកដាច់ពីស្នាព្រះហស្តរបស់ទ្រង់យ៉ាងណា ទ្រង់នៅតែរក្សាទំនាក់ទំនងមួយជាមួយនឹងមនុស្ស ដែលនៅក្នុងទំនាក់ទំនងនោះទ្រង់បានជិតស្និទ្ធជាមួយពួកគេ។ បន្ទាប់ទៀតយើងនឹងមើលថាតើការនេះអាចកើតឡើងដោយរបៀបណា។

យើងអាចមើលឃើញ ភាពវិសុទ្ធរបស់ព្រះជាម្ចាស់នៅក្នុងឥរិយាបថ និង សកម្មភាពរបស់ទ្រង់។ នៅក្នុងភាពវិសុទ្ធរបស់ទ្រង់ រួមមានការសព្វព្រះហឫទ័យនឹងអ្វីដែលល្អ និង មិនសព្វព្រះហឫទ័យនឹងការអាក្រក់។ ដូច្នេះ ព្រះជាម្ចាស់គាប់ព្រះទ័យជាមួយនឹងភាពទៀងត្រង់ និង ភាពល្អត្រឹមត្រូវ ហើយទ្រង់កាត់អង្គទ្រង់ចេញពីមនុស្សអាក្រក់ និង ផ្ដន្ទាទោសមនុស្សអាក្រក់។

ការកាត់ផ្ដាច់អង្គព្រះជាម្ចាស់ ចេញពីមនុស្សគឺមានភាពចាំបាច់ណាស់ ដោយសារតែភាពមានបាបរបស់មនុស្ស។ សេចក្ដីពិតនេះ ត្រូវបានបង្ហាញឲ្យឃើញជាច្រើនលើក នៅក្នុងគម្ពីរសម្ពន្ធមេត្រីចាស់ ។ ព្រះជាម្ចាស់បានបង្គាប់ឲ្យលោកម៉ូសេ កំណត់ព្រំដែននៅជុំវិញភ្នំស៊ីណៃ (គម្ពីរនិក្ខមនំ ១៩:១២-១៣, ២១-២៥) ។ ទ្រង់សព្វព្រះហឫទ័យឲ្យប្រជាជាតិអ៊ីស្រាអែលដឹងថាមនុស្សអាក្រក់ត្រូវតែកាត់ឲ្យដាច់ចេញពីព្រះជាម្ចាស់ដ៏វិសុទ្ធ។

ការកាត់ផ្ដាច់ព្រះជាម្ចាស់ចេញពីមនុស្សមានបាប ក៏ត្រូវបានគេឃើញមាននៅក្នុងសញ្ញារបស់ជំរំ ឬ ព្រះពន្លា ដែលព្រះជាម្ចាស់បានបង្គាប់ឲ្យលោកម៉ូសេសាងសង់នៅក្នុងវាលរហោស្ថាន។ កន្លែងពិសេសមួយនៃជំរំនោះ ត្រូវបានគ្របដោយវាំងនន (សូមមើលគម្ពីរនិក្ខមនំ ២៦:៣៣)។ មានតែមនុស្សម្នាក់តែប៉ុណ្ណោះ អាចត្រូវបានអនុញ្ញាតឲ្យចូលទៅក្នុងកន្លែងមួយនោះ ម្នាក់នោះគឺបូជាចារ្យដ៏វិសុទ្ធម្នាក់ដែលត្រូវបានអនុញ្ញាតឲ្យចូល មួយឆ្នាំម្ដងដើម្បីប្រោះឈាមនៅលើគម្របហិប (សូមមើលគម្ពីរលេវីវិន័យ ១៦)។ លោកបានធ្វើដូច្នេះ ដើម្បីរំដោះបាបរបស់មនុស្ស នៅក្នុងព្រះវត្តមានរបស់ព្រះជាម្ចាស់ដ៏វិសុទ្ធ។ ដោយធ្វើរបៀបនេះ ព្រះជាម្ចាស់សម្ដែងឲ្យមនុស្សឃើញថា ទ្រង់មិនសព្វព្រះហឫទ័យចំពោះអំពើបាបរបស់ពួកគេកម្រិតណា។

នៅក្នុងគម្ពីរសម្ព័ន្ធមេត្រីចាស់ មានភស្តុតាងជាច្រើនដែលបង្ហាញពីភាពវិសុទ្ធរបស់ព្រះជាម្ចាស់។ គម្ពីរអេសាយ ៥៩:២ និង គម្ពីរហាបាគូក១:១៣ បង្រៀនថាអំពើបាបកាត់ផ្ដាច់ព្រះជាម្ចាស់ចេញពីមនុស្សមានបាប ហើយវាកាត់ផ្ដាច់មនុស្សមានបាបពីព្រះជាម្ចាស់ ។ គម្ពីរយ៉ូប៤០:៣-៥ និងគម្ពីរអេសាយ ៦:៥-៧ បង្ហាញយើងថាប្រសិនបើយើងមានការយល់ដឹងយ៉ាងពិតប្រាកដអំពីភាពវិសុទ្ធរបស់ព្រះជាម្ចាស់ នោះយើងក៏នឹងដឹងថាអំពើបាបគួរឲ្យខ្លាចយ៉ាងណា។ ពេលដែលយើងឃើញពីភាពវិសុទ្ធដែលគ្មានដែនកំណត់របស់ព្រះជាម្ចាស់ នោះយើងមានអារម្មណ៍សោកសៅចំពោះអំពើបាប យើងនឹងលន់តួបាប ហើយធ្វើឲ្យយើងម្នាក់ៗបានចេះបន្ទាបខ្លួន។

## *លំហាត់អនុវត្តន៍*

---

១ ចូរបំពេញចន្លោះបន្ទាត់ខាងក្រោម ដោយយោងទៅតាមខគម្ពីរខាងលើ។

ក) ព្រះជាម្ចាស់មិនអាចប៉ះពាល់អ្វីដែលមិនបរិសុទ្ធបានឡើយ ព្រោះទ្រង់.........................។

ខ) អំពើបាបបណ្ដាលឲ្យយើង ..........................................................ពីព្រះជាម្ចាស់។

គ) ការយល់ដឹងអំពីភាពវិសុទ្ធឥតខ្ចោះរបស់ព្រះជាម្ចាស់ អាចធ្វើឲ្យយើងដឹងថា..................
.....................................................................................................................។

---

ភាពវិសុទ្ធរបស់ព្រះជាម្ចាស់ក៏ជាប្រធានបទនៅក្នុងបទគម្ពីរសម្ព័ន្ធមេត្រីថ្មីជាច្រើនផងដែរ។ យើងបានឃើញនៅក្នុងឧទាហរណ៍នៃគម្ពីរសម្ព័ន្ធមេត្រីចាស់រួចមកហើយ ថាមនុស្សគ្មានសិទ្ធិចូលទៅកាន់ព្រះជាម្ចាស់ដោយផ្ទាល់នោះទេ ពួកគេក៏មិនអាចចូលទៅកាន់ព្រះជាម្ចាស់ដោយប្រើការខិតខំប្រឹងប្រែងផ្ទាល់ខ្លួនរបស់ពួកគេបានដែរ។ នៅក្នុងគម្ពីរសម្ព័ន្ធមេត្រីចាស់ បូជាចារ្យម្នាក់បានចូលទៅក្នុងព្រះវត្តមានរបស់ព្រះជាម្ចាស់ ដើម្បីធ្វើពិធីរំដោះបាប សម្រាប់ប្រជាជន។ តែឥឡូវនេះការរំដោះបាប បានធ្វើឡើងតាមរយៈការបូជាព្រះរាជបុត្រារបស់ព្រះជាម្ចាស់ គឺព្រះយេស៊ូគ្រិស្ដ។ យោងទៅតាមគម្ពីររ៉ូម៥:២ និង គម្ពីរអេភេសូ ២:១៣-១៨ ប្រសិនបើយើងចង់ចូលទៅកាន់ព្រះជាម្ចាស់ ត្រូវតែចូលទៅតាមរយៈគុណូបការៈរបស់ព្រះយេស៊ូ ។ គម្ពីរ១ពេត្រុស៣:១៨ ប្រាប់យើងថា ភាពមិនស្អាត និង ភាពទុច្ចរិតទាំងអស់របស់យើង ត្រូវបានគ្របដណ្ដប់និង លើកលែងឲ្យដោយព្រះសង្គ្រោះដ៏សុចរិតរបស់យើង ដើម្បីនាំយើងឲ្យចូលទៅក្នុងព្រះវត្តមានរបស់ព្រះជាម្ចាស់ដ៏វិសុទ្ធ។

## *លំហាត់អនុវត្តន៍*

២ បទគម្ពីរទាំងនេះបានបង្រៀនយើងថា មធ្យោបាយតែមួយគត់ដែលអាចឲ្យយើងចូលទៅកាន់ព្រះវត្តមានរបស់ព្រះជាម្ចាស់ដ៏វិសុទ្ធ គឺតាមរយៈការរំដោះបាប ដែលបានប្រទានមកដោយ
ក) បូជាចារ្យម្នាក់
ខ) ការព្យាយាមឲ្យបានវិសុទ្ធរបស់យើង។
គ) ព្រះសង្គ្រោះរបស់យើងគឺព្រះយេស៊ូគ្រិស្ត។

យើងមិនអាចនិយាយអំពីព្រះជាម្ចាស់ ដោយមិននិយាយអំពីភាពសុចរិត និង ភាពយុត្តិធម៌របស់ទ្រង់បាននោះទេ។ អ្នកប្រាជ្ញខាងព្រះគម្ពីរជាច្រើនរូប បានញែកលក្ខណៈទាំងនេះ ជាគុណលក្ខណៈដោយឡែកផ្សេងទៀតនៃត្រៃឯកភាពពេញលេញ ប៉ុន្តែភាពសុចរិត និង ភាពយុត្តិធម៌គឺជាលទ្ធផលដែលបានមកពីភាពវិសុទ្ធរបស់ព្រះជាម្ចាស់ផ្ទាល់តែម្តង។ លក្ខណៈទាំងនេះគឺជាផ្នែកមួយនៃភាពវិសុទ្ធរបស់ទ្រង់ ដែលឃើញមាននៅក្នុងការដែលទ្រង់ធ្វើទៅលើមនុស្សលោក។

ទីមួយ ភាពវិសុទ្ធរបស់ព្រះជាម្ចាស់ត្រូវបានបង្ហាញឲ្យឃើញតាមរយៈ*ភាពសុចរិត*។ ទ្រង់បានបង្កើតរដ្ឋាភិបាលដែលមានសីលធម៌នៅក្នុងពិភពលោក។ នេះមានន័យថា ទ្រង់បានប្រទានច្បាប់យុត្តិធម៌ (ភាពស្មើគ្នា និង ភាពត្រឹមត្រូវ) ដើម្បីឲ្យមនុស្សរស់នៅក្រោមច្បាប់នោះ។ ទីពីរ ភាពវិសុទ្ធរបស់ទ្រង់ ត្រូវបានបង្ហាញឲ្យឃើញតាមរយៈ *ភាពយុត្តិធម៌* ។ ទ្រង់គ្រប់គ្រង ច្បាប់របស់ទ្រង់យ៉ាងយុត្តិធម៌ ទ្រង់ប្រទានរង្វាន់ឲ្យអ្នកស្ដាប់បង្គាប់តាមច្បាប់របស់ទ្រង់ ហើយទ្រង់ដាក់ទោសអស់អ្នកដែលធ្វើល្មើសច្បាប់ទាំងនេះ។

ភាពសុចរិតរបស់ព្រះជាម្ចាស់ ត្រូវបានបង្ហាញឲ្យឃើញតាមរយៈការសព្វព្រះហឫទ័យភាពវិសុទ្ធដែលមាននៅក្នុងមនុស្សលោក។ ទ្រង់មិនត្រឹមតែជាព្រះជាម្ចាស់ដ៏វិសុទ្ធប៉ុណ្ណោះទេ ប៉ុន្តែទ្រង់តម្រូវឲ្យមនុស្សរបស់ទ្រង់បានវិសុទ្ធផងដែរ។ ភាពយុត្តិធម៌របស់ទ្រង់ ត្រូវបង្ហាញឲ្យឃើញតាមរយៈការវិនិច្ឆ័យទោសបាប។ ដោយសារតែទ្រង់មិនអាចទ្រាំទ្រជាមួយនឹងអំពើបាបបាន ទ្រង់ត្រូវតែដាស់ទោសអស់អ្នកដែលប្រព្រឹត្តិអំពើបាប។

## *លំហាត់អនុវត្តន៍*

៣ ចូរអានគម្ពីរហេប្រឺ១២:១០,១៤ ហើយឆ្លើយនឹងសំណួរនេះ៖ តើព្រះជាម្ចាស់តម្រូវឲ្យធ្វើអ្វីខ្លះ បន្ទាប់ពីខ្ញុំបានក្លាយជាគ្រិស្តបរិស័ទម្នាក់ និងបានបែរចេញពីជីវិតដែលពេញដោយបាបរបស់ខ្ញុំហើយ?

..............................................................................................................................

ភាពវិសុទ្ធដែលមាននៅក្នុងគុណសម្បត្តិនៃជីវិតរបស់គ្រិស្តបរិស័ទគឺមិនគ្រាន់តែជាការ *មិនធ្វើអ្វីដែលខុសនោះទេ*។ វាក៏ជា*ការធ្វើរឿងត្រឹមត្រូវ* ផងដែរ។ នៅក្នុងសកម្មភាពជាក់ស្តែង វាគឺជាការបង្ហាញនៅក្នុងការរស់នៅ និង ការធ្វើអ្វីដែលសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់នាំយើងឲ្យធ្វើទៅចំពោះអ្នកដទៃ។ វាធ្វើឲ្យយើងមានចិត្ត និង ចេះបារម្ភពីអ្នកដទៃដែលនៅជុំវិញយើង។

ឧទាហរណ៍ យើងអាចរក្សាការស្ដាប់បង្គាប់ព្រះជាម្ចាស់ នៅពេលដែលយើងជួយបំពេញតម្រូវការរបស់មនុស្ស។ យើងមិនចាំបាច់ត្រូវធ្វើឲ្យខុសគោលការណ៍របស់គ្រិស្តបរិស័ទ ដើម្បីគ្រាន់តែចង់ជួយអ្នកដទៃប៉ុណ្ណោះទេ។ រឿងប្រស្នារបស់ព្រះយេស៊ូនៅក្នុងគម្ពីរលូកា ១០:២៩-៣៧ បានបង្ហាញពីឧត្ដមគតិរបស់គ្រិស្តបរិស័ទ (ខ្នាតគំរូនៃភាពឥតខ្ចោះ) ដែលយើងគប្បីយកមកផ្ទុះបញ្ចាំងមកកាន់យើងខ្លួនឯង។ ក្នុងពេលជាមួយគ្នានោះដែរ ភាពវិសុទ្ធស្ដែងបញ្ជាក់ពីសកម្មភាពដែលបង្ហាញនូវឧត្ដមគតិរបស់យើងក្នុងរបៀបជាក់ស្ដែងទៅកាន់អ្នកជិតខាងរបស់យើង។

# លំហាត់អនុវត្តន៍

៤ ចូរអានគម្ពីរលូកា១០:២៩-៣៧ ។ ចូរប្រាប់ពីថានរណាម្នាក់នៅក្នុងចំណោមអ្នកខាងក្រោមនេះដែលបង្ហាញពីឧត្ដមគតិនៃភាពវិសុទ្ធរបស់គ្រិស្តបរិស័ទតាមរយៈទង្វើ? ហេតុអ្វី? ៖ បុរសម្នាក់ពីក្រុមលេវី សាសន៍សាម៉ារី ឬ បូជាចារ្យ។

ដូចដែលយើងបានឃើញនៅក្នុងគម្ពីរហេប្រឺ១២:១០ និង ខ១៤ ហើយថា ព្រះគម្ពីរបានជំរុញឲ្យយើងរាល់គ្នារស់នៅក្នុងជីវិតដែលវិសុទ្ធ ឬ ជីវិតដាច់ពីគេ។ មនុស្សអាចស្ដាប់បង្គាប់តាមបទបញ្ញានេះបាន ហើយក្នុងពេលជាមួយគ្នា គេក៏អាចចូលរួមជាមួយជីវិតក្នុងសហគមន៍ ដូចដែលព្រះយេស៊ូបានបង្រៀននៅក្នុងគម្ពីរម៉ាថាយ ៥:១៣-១៦ ដែរ។ បទគម្ពីរនេះបង្រៀនថា យើងមិនត្រូវបាត់ភាពវិសុទ្ធរបស់យើងឡើយ ប៉ុន្តែយើងត្រូវធ្វើជាគំរូសម្រាប់អ្នកដទៃវិញ។ ដូច្នេះ គ្រិស្តបរិស័ទនឹងមិនយកខ្លួនពួកគេទៅបៀត អ្វីដែលព្រះគម្ពីរសម្ដែងមេត្រីបានហាមឃាត់នោះទេ។ ប៉ុន្តែពួកគេនឹងធ្វើអ្វីៗគ្រប់យ៉ាងដែលអាចធ្វើបាន ដើម្បីបម្រើគ្រួសាររបស់ពួកគេ និង អ្នកជិតខាងរបស់ពួកគេ ព្រមទាំងបង្ហាញថាពួកគេពិតជាយកចិត្តទុកដាក់ជាមួយនឹងអ្នកទាំងនោះមែន។

# លំហាត់អនុវត្តន៍

៥ នៅពេលយើងគិតពីភាពសុចរិត និង ភាពយុត្តិធម៌របស់ព្រះជាម្ចាស់ យើងទទួលបានគំរូល្អៗអំពីរបៀបដែលយើងគួរធ្វើទៅលើកូនៗរបស់យើង។ តើចម្លើយមួយណា នៅខាងក្រោមនេះជាអ្វីដែលយើងនឹងធ្វើ? (ចូរជ្រើសរើសចម្លើយដែលល្អបំផុត)។ យើងនឹង.......

ក) ដាក់ទោសកូនរបស់យើងឲ្យបានញឹកញាប់ ដើម្បីរំឭកពួកគេថា ពួកគេត្រូវតែល្អគ្រប់ពេល។

ខ) មានយុត្តិធម៌នៅក្នុងការទាមទាររបស់យើង ឲ្យរង្វាន់ពួកគេនៅពេលពួកគេស្ដាប់បង្គាប់ ហើយដាក់ទោសពួកគេនៅពេលពួកគេមិនស្ដាប់បង្គាប់។

គ) ព្រមានពួកគេថា ពួកគេនឹងត្រូវទទួលការដាក់ទោស ប្រសិនបើពួកគេមិនស្ដាប់បង្គាប់ ប៉ុន្តែមិនដែលធ្វើការដាក់ទោសណាមួយឡើយ ដ្បិតធ្វើដូច្នោះនឹងធ្វើឲ្យពួកគេមានការសង្ស័យចំពោះក្ដីស្រឡាញ់របស់យើងសម្រាប់ពួកគេ។

សំណួរទី៥ នេះរំឭកយើងថា យើងត្រូវស្គាល់ និង យល់ គោលការណ៍នៅក្នុងព្រះគម្ពីរទាក់ទងនឹងវិន័យ។ យោងទៅតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ ឪពុកម្តាយដែលមិនប្រដៅកូនរបស់ខ្លួនពួកគេឲ្យបានជាប់លាប់នោះទេ គឺដូចនាំឲ្យពួកគេស្លាប់យ៉ាងដូច្នោះដែរ។ (គម្ពីរសុភាសិត ១៩:១៨) ។ គម្ពីរហេព្រើ ១២:៦ និងគម្ពីរវិវរណៈ ៣:១៩ បង្រៀនថាព្រះជាម្ចាស់ប្រដៅអ្នកដែលទ្រង់ស្រឡាញ់។ ប្រសិនបើយើងពិតជាស្រឡាញ់កូនរបស់យើងមែន យើងត្រូវប្រដៅពួកគេដើម្បីឲ្យពួកគេបានល្អ (សូមមើលគម្ពីរហេព្រើ១២:៥-១១)។

## *លំហាត់អនុវត្តន៍*

៦ ចូរគូសរង្វង់ជុំវិញអក្សរនៅខាងមុខចម្លើយត្រឹមត្រូវ ដែលនិយាយអំពីសារៈសំខាន់នៃភាពវិសុទ្ធរបស់ព្រះជាម្ចាស់។

ក) ភាពវិសុទ្ធគឺលក្ខណសម្បត្តិរបស់ព្រះជាម្ចាស់ដែលបង្ហាញឲ្យឃើញពីភាពឥតខ្ចោះខាងឯសីលធម៌របស់ទ្រង់។

ខ) ដោយសារតែភាពវិសុទ្ធដ៏គ្មានដែនកំណត់របស់ទ្រង់ ព្រះជាម្ចាស់មិនអាចរក្សាទំនាក់ទំនងជិតស្និទ្ធជាមួយប្រជារាស្ត្ររបស់ទ្រង់ឡើយ។

គ) ផ្នត់គំនិតនៃភាពវិសុទ្ធ រួមមានការស្រឡាញ់អ្វីដែលល្អ និង ប្រកបខ្ជាប់នូវក្រិតវិន័យរបស់ព្រះជាម្ចាស់ និង ការស្អប់អំពើអាក្រក់។

ឃ) នៅក្នុងជំនាន់សម្ព័ន្ធមេត្រីចាស់ ព្រះជាម្ចាស់បានបង្ហាញឲ្យឃើញយ៉ាងច្បាស់ថា ទ្រង់នឹងមិនផ្តាច់អង្គទ្រង់ចេញពីប្រជារាស្ត្ររបស់ទ្រង់ឡើយ ទោះបីជាពួកគេប្រព្រឹត្តិអំពើបាបក៏ដោយ។

ង) របៀបដែលព្រះជាម្ចាស់គ្រប់គ្រងមនុស្សរបស់ទ្រង់ គឺជាលទ្ធផលដែលបានមកពីលក្ខណសម្បត្តិខាងឯសីលធម៌របស់ទ្រង់។

ច) ដោយសារព្រះជាម្ចាស់យុត្តិធម៌ ទ្រង់មិនត្រឹមតែប្រទានយុត្តិធម៌ដ៏វិសុទ្ធនោះទេ ប៉ុន្តែទ្រង់ក៏បានប្រទានមធ្យោបាយនៃការរំដោះបាប ប្រសិនបើប្រជារាស្ត្ររបស់ទ្រង់ខកខានមិនស្តាប់បង្គាប់ទ្រង់។

ឆ) ផ្នត់គំនិតនៃភាពវិសុទ្ធ មានន័យថាមិនធ្វើអ្វីដែលខុស។

# សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់

**វត្ថុបំណងទី២.** *ប្រាប់ថា និយមន័យនៃស្រឡាញ់របស់ព្រះជាម្ចាស់សម្រាប់យើងជាអ្វី និង ប្រាប់ពីរបៀបដែលសេចក្តីស្រឡាញ់នោះស្តែងចេញមក។*

ឧបមាថា មានបុរសម្នាក់បានប្រាប់ទៅនារីម្នាក់ថាគាត់ស្រឡាញ់នាង ប៉ុន្តែក្រោយពីពួកគេបានរៀបការហើយ អ្វីដែលគាត់ធ្វើមានតែអ៊ូរទាំដាក់នាង។ គាត់មិនបានបង្ហាញការចាប់អារម្មណ៍ទៅលើអ្វីដែល

មានសារៈសំខាន់សម្រាប់នាងនោះទេ ហើយគាត់មិនខិតខំធ្វើល្អចំពោះនាងសូម្បីតែបន្តិច។ តើអ្នកគិតយ៉ាងណាចំពោះក្តីស្រឡាញ់របស់គាត់សម្រាប់នាង?

ព្រះជាម្ចាស់ទ្រង់មិនយ៉ាងដូច្នេះទេ។ ទ្រង់ស្រឡាញ់អ្នក និង ខ្ញុំក្រៃលែង ហើយទ្រង់មិនត្រឹមតែបង្ហាញក្តីស្រឡាញ់នោះតាមរយៈព្រះបន្ទូល និង ការសន្យារបស់ទ្រង់នោះទេ តែទ្រង់ក៏បង្ហាញតាមរយៈអ្វីដែលទ្រង់ធ្វើផងដែរ។

គ្មានអ្វីដែលយើងអាចធ្វើបានដើម្បី សមនឹងទទួល ឬ រកបានសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់នោះឡើយ។ គ្មានអ្វីដែលយើងអាចនិយាយ ឬ ធ្វើដើម្បីតម្រូវឲ្យព្រះជាម្ចាស់មកស្រឡាញ់យើងបាននោះទេ។ ការស្រឡាញ់គឺជាផ្នែកមួយនៃនិស្ស័យរបស់ទ្រង់។ ទ្រង់ស្រឡាញ់ពិភពលោក ។ ទ្រង់ស្រឡាញ់យើង។

ព្រះជាម្ចាស់បានបង្ហាញយ៉ាងជាក់ស្តែង ថាទ្រង់ស្រឡាញ់យើងកម្រិតណា។ មានអ្នកខ្លះចាត់ទុក *ភាពល្អ សេចក្តីមេត្តាករុណា ការអត់ធ្មត់* និង *ភាពស្មោះត្រង់* ថាជាគុណលក្ខណៈដោយឡែករបស់ព្រះជាម្ចាស់ ប៉ុន្តែខ្ញុំចាត់ទុកលក្ខណៈទាំងនេះថាជាផ្នែកមួយនៃក្តីស្រឡាញ់របស់ទ្រង់។ អ្នកប្រហែលជានឹងគិតឃើញពីផ្នែកផ្សេងទៀតនៃក្តីស្រឡាញ់របស់ទ្រង់ ដែលអាចបន្ថែមនៅក្នុងគុណលក្ខណៈទាំងនេះ។ គុណលក្ខណៈទាំងនេះ បង្ហាញយើងថា យើងសំខាន់យ៉ាងណាសម្រាប់ទ្រង់។ គុណលក្ខណៈទាំងនេះក៏រំឭកយើងថា ទ្រង់យកព្រះទ័យទុកដាក់ចំពោះយើងយ៉ាងណាដែរ។

## លំហាត់អនុវត្តន៍

៧ ចូរអានគម្ពីរយ៉ូហាន៣:១៦; ១៧:២៤ គម្ពីរ១យ៉ូហាន៤:៩-១០ និងគម្ពីរវិវរណៈ១:៤-៥។ ខគម្ពីរទាំងនេះបង្ហាញថា សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់មានសកម្មភាព។ តើទង្វើបែបណាដែលបង្ហាញពីសេចក្តីស្រឡាញ់នេះ?

.................................................................................................................................

៨ ចូរអានគម្ពីរយ៉ូហាន១៣:៣៤-៣៥; ១៤:១៥; ១៥:១៣-១៤ និងគម្ពីរ១យ៉ូហាន៥:២-៣ ។ ចូរប្រាប់ពីមធ្យោបាយពីរយ៉ាងដែលយើងបង្ហាញក្តីស្រឡាញ់របស់យើងសម្រាប់ព្រះជាម្ចាស់។

.................................................................................................................................

.................................................................................................................................

នៅក្នុងគម្ពីរសម្ព័ន្ធមេត្រីចាស់ ព្រះជាម្ចាស់តែងតែត្រូវបានបង្ហាញថាជាអ្នកចម្បាំងដ៏អស្ចារ្យ និង មានឫទ្ធានុភាពម្នាក់។ ខ្ញុំរីករាយក្រៃលែង ដែលឃើញទ្រង់ក៏ត្រូវបានគេបង្ហាញថាជាព្រះជាម្ចាស់ដែលពេញដោយក្តីស្រឡាញ់។ ឧទាហរណ៍មួយដ៏អស្ចារ្យជាងគេ អំពីសេចក្តីស្រឡាញ់របស់ទ្រង់ បង្ហាញថាព្រះអង្គម្ចាស់ជាមេបំផ្លាញដែលពេញដោយកំហឹង ដែលហៀបនឹងដាក់ទោសទីក្រុងអាក្រក់ ប៉ុន្តែទ្រង់រារែក ទ្រង់ស្ទាក់ស្ទើរនឹងបំផ្លាញទីក្រុងនោះ។ ហេតុអ្វីបានជាទ្រង់មិនធ្វើតាមផែនការរបស់ព្រះអង្គតែម្តងទៅ? ទោះជាយ៉ាងណាក្តី កំពែងបានស្រុតទៅហើយ និង គ្មានអ្វីទៅរាំងផ្លូវទៀតនោះទេ។ ប៉ុន្តែមានអ្វីម្យ៉ាង ធ្វើឲ្យទ្រង់ស្ទាក់ស្ទើរ នោះគឺក្តីស្រឡាញ់របស់ទ្រង់សម្រាប់មនុស្សអាក្រក់ទាំងនោះ។ ទ្រង់មានព្រះបន្ទូលថា៖ "

យើងស្វែងរកក្នុងចំណោមពួកគេ ក្រែងលោយើញនរណាម្នាក់មានគំនិតសង់កំពែងការពារក្រុង ហើយឈរនៅចំពោះមុខយើងត្រង់កន្លែងបាក់បែក ដើម្បីការពារស្រុកទេសកុំអោយវិនាស តែយើងរកពុំបានសោះ" (គម្ពីរអេសេគាល ២២:៣០)។ ប្រសិនបើមានមនុស្សសុចរិតណាម្នាក់ បានទៅទីនោះហើយទូលអង្វរសុំក្តីមេត្តាពីទ្រង់ ទ្រង់ប្រហែលជាអាចលើកលែងឲ្យទីក្រុងនោះ។ ការនេះពិតជាបានបង្ហាញពីក្តីស្រឡាញ់របស់ទ្រង់យ៉ាងខ្លាំង។

លោកដាវីឌ លោកអេសាយ និង លោកយេរេមា បង្ហាញអំពីព្រះជាម្ចាស់ថាជា *ឪពុក*។ តើមានអ្វីទាក់ទងនឹង ឪពុកដ៏ល្អម្នាក់សម្រាប់កូនៗរបស់គាត់ ដែលនាំឲ្យពួកលោកធ្វើការប្រៀបធៀបមួយនេះ? លោកដាវីឌបានមានប្រសាសន៍ថា៖ ព្រះជាម្ចាស់មានព្រះទ័យអាណិតអាសូរចំពោះបុត្ររបស់ទ្រង់។ ទ្រង់ជ្រាបថា ពួកគេទន់ខ្សោយមិនអាចជួយខ្លួនឯងបានទេ (គម្ពីរទំនុកតម្កើង ១០៣:១៣-១៤) ។ លោកអេសាយបានចាត់ទុកព្រះជាម្ចាស់ដូចជាឪពុកមាន *ក្តីមេត្តាករុណា* (គម្ពីរអេសាយ៦៣:១៦; ៦៤:៨)។ លោកយេរេមាមើលទៅកាន់ព្រះជាម្ចាស់ថាជាឪពុកដែល បន្ទាប់ពីដាក់ទោសកូនណាដែលមិនស្តាប់បង្គាប់ ហើយនាំពួកគេទៅផ្ទះវិញដោយទន់ភ្លន់ (គម្ពីរយេរេមា ៣១:៧-៩)។

នៅក្នុងគម្ពីរសម្ព័ន្ធមេត្រីថ្មី យើងមានឧទាហរណ៍ដ៏ឧត្តមអស្ចារ្យ អំពីសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់។ នៅពេលដែលព្រះយេស៊ូបានយាងមកលើផែនដី ដើម្បីបង់លោះទោសបាបរបស់យើង ទ្រង់បានបង្ហាញពីថ្លៃឈ្នួលដ៏អាក្រក់នៃអំពីបាប (សេចក្តីស្លាប់)។ ទ្រង់បានប្រទានការសង្គ្រោះមកឲ្យយើង ដែលមានតម្លៃមិនអាចកាត់ថ្លៃបាន នោះគឺព្រះជន្មទ្រង់ផ្ទាល់ (គម្ពីរយ៉ូហាន ៤:១៦-១៧) ។ ដ្បិតព្រះជាម្ចាស់ស្រឡាញ់យើងយ៉ាងខ្លាំង យើងដឹងថាទ្រង់នឹងមិនអនុញ្ញាតឲ្យមានរឿងអ្វីកើតឡើងនៅក្នុងជីវិតរបស់យើង ដែលមិនអាចផ្តល់ប្រយោជន៍សម្រាប់យើងបាននោះទេ ប្រសិនបើយើងស្រឡាញ់ទ្រង់។ យើងអាចទុកចិត្តលើក្តីស្រឡាញ់របស់ទ្រង់ មិនថាកាលៈទេសៈរបស់យើងទៅជាយ៉ាងណាក៏ដោយ។ ក្តីស្រឡាញ់របស់ទ្រង់រំដោះយើងពីភាពភ័យខ្លាច និង ទារុណកម្មនៃភ័យខ្លាច (គម្ពីរ១យ៉ូហាន ៤:១៨ គម្ពីរ២ធីម៉ូថេ ១:៧)។

## លំហាត់អនុវត្តន៍

៩ ដោយសរសេរនៅក្នុងសៀវភៅកត់ត្រារបស់អ្នក ចូររៀបរាប់អំពីលក្ខណសម្បត្តិរបស់ព្រះជាម្ចាស់ ដែលអ្នកអាចរកឃើញនៅក្នុងគម្ពីរអេសាយ ៤៣:១-៥។ ចូរអ្នករកឲ្យបានគុណលក្ខណៈធម្មជាតិរបស់ទ្រង់បីយ៉ាង និង គុណលក្ខណៈខាងឯសីលធម៌របស់ទ្រង់ពីរយ៉ាង។

១០ តើអ្នកមានមិត្តភក្តិណាដែលមិនដឹងថា ព្រះជាម្ចាស់ស្រឡាញ់ពួកគេដែរឬទេ? ចូរអានគម្ពីរម៉ាថាយ ២៤:១៤; ២៨:១៩ និង គម្ពីរកិច្ចការ ១:៨ ។ ដោយផ្អែកទៅលើបទគម្ពីរទាំងនេះ តើអ្វីជាទំនួលខុសត្រូវរបស់អ្នកសម្រាប់អស់អ្នកដែលមិនដឹងអំពីក្តីស្រឡាញ់របស់ព្រះជាម្ចាស់? ចូរសរសេរចម្លើយដាក់ក្នុងសៀវភៅកត់ត្រារបស់អ្នក។

គម្ពីរអេសេគាល ១៨:១-៣២ បង្ហាញពីក្តីស្រឡាញ់ដ៏អស្ចារ្យដែលព្រះជាម្ចាស់មានសម្រាប់ប្រជារាស្ត្ររបស់ទ្រង់។ នៅពេលខ្លះពួកគេមិនបានឃើញពីមូលហេតុនៃទុក្ខលំបាករបស់ពួកគេ ព្រះជាម្ចាស់មានព្រះបន្ទូលថា អ្វីដែលទ្រង់សព្វព្រះទ័យចង់បានពីពួកគេគឺការបម្រើដោយស្តាប់បង្គាប់។ ការដាក់ទោសត្រូវ

បានធ្វើឡើង ដើម្បីបង្វែរអារម្មណ៍របស់ពួកគេមករកទ្រង់ និងដើម្បីនាំឲ្យមានការផ្សះផ្សា និង ព្យាបាល ទំនាក់ទំនងរបស់ពួកគេជាមួយនឹងទ្រង់។ ខទី៣១ និង ទី៣២ បញ្ជាក់ពីកម្រិតនៃក្តីស្រឡាញ់របស់ព្រះជាម្ចាស់ដែលមានចំពោះសាសន៍អ៊ីស្រាអែល និង បំណងព្រះហឫទ័យដ៏អស់កល្បជានិច្ចរបស់ទ្រង់សម្រាប់ការសង្គ្រោះប្រជាជនរបស់ទ្រង់៖

> ចូរបោះបង់ចោលអំពើទុច្ចរិតទាំងអស់ដែលអ្នករាល់គ្នាបានប្រព្រឹត្ត។ ចូរមានចិត្តគំនិតថ្មី និងវិញ្ញាណថ្មី! ជនជាតិអ៊ីស្រាអែលអើយអ្នករាល់គ្នាមិនគួរស្លាប់ឡើយ ដ្បិតយើងមិនសប្បាយចិត្តនឹងអោយនរណាម្នាក់ស្លាប់ទេ ចូរវិលមករកយើងវិញ នោះអ្នករាល់គ្នានឹងរស់រានមានជីវិត» -នេះជាព្រះបន្ទូលរបស់ព្រះជាអម្ចាស់ -។

## *លំហាត់អនុវត្តន៍*

១១ ចូរជ្រើសរើសចម្លើយត្រឹមត្រូវ ដែលនិយាយអំពីអត្ថន័យនៃក្តីស្រឡាញ់របស់ព្រះជាម្ចាស់សម្រាប់យើង និង របៀបដែលក្តីស្រឡាញ់នោះត្រូវបានបង្ហាញមក។ សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់

- ក) បង្ហាញថា ទោះបីមនុស្សធ្វើយ៉ាងណាតបទៅចំពោះទ្រង់ ទ្រង់នឹងទតរំលងអំពើបាបរបស់ពួកគេ។
- ខ) បង្ហាញពីសេចក្តីល្អ សេចក្តីមេត្តាករុណា ការអត់ធ្មត់ និង ព្រះគុណ នៅក្នុងទំនាក់ទំនងសម្ព័ន្ធភាពរបស់ទ្រង់ជាមួយមនុស្ស និង សេចក្តីស្រឡាញ់នេះ បានស្តែងឡើងនៅតាមរបៀបជាក់ស្តែងមួយ ដូចជាអត់ទោសបាប។
- គ) បណ្តាលឲ្យមានការដាក់ទោស ហើយសេចក្តីស្រឡាញ់នេះបង្ហាញឲ្យឃើញតាមរយៈភាពមិនស្ទាក់ស្ទើររបស់ទ្រង់ ហើយប្រទានឱកាសមួយទៀតឲ្យមនុស្សដើម្បីឲ្យពួកគេបានបម្រើទ្រង់។

# ខ. រាជកិច្ចនៃការបង្កើតរបស់ព្រះជាម្ចាស់

**វត្ថុបំណងទី៣.** *បកស្រាយសកម្មភាពនៃការបង្កើតរបស់ព្រះជាម្ចាស់ និង សារសំខាន់នៃការបង្កើតនោះសម្រាប់យើង។*

ពេលនេះយើងនឹងពិចារណាអំពីព្រះរាជកិច្ចរបស់ព្រះជាម្ចាស់៖ ១) *ព្រះរាជ្យកិច្ចនៃការបង្កើត* របស់ទ្រង់ ២) ការគ្រងរាជ្យរបស់ទ្រង់នៅលើសាកលលោក ដែលរួមបញ្ចូល *ការថែរក្សា* ឬ *ការការពារ* របស់ទ្រង់ចំពោះស្នាព្រះហស្តរបស់ទ្រង់ និង ៣) *ការផ្គត់ផ្គង់* របស់ទ្រង់ ដែលនាំឲ្យមានបំណងព្រះហឫទ័យដ៏អស់កល្បជានិច្ចរបស់ទ្រង់។ ទីមួយ យើងនឹងមើលទៅលើអ្វីដែលព្រះគម្ពីរបង្រៀនអំពីការបង្កើតរបស់សព្វសារពើរបស់ទ្រង់។

មនុស្សតែងតែមានឈ្មោះល្បីនៅក្នុងប្រវត្តិសាស្ត្រ មិនដោយសារតែពួកគេ *ជានរណា* នោះទេ ប៉ុន្តែដោយសារតែអ្វីដែលពួកគេបាន *ធ្វើ*។ ជាឧទាហរណ៍ លោកស្រី ម៉ារា ឃើរី (Madame Marie Curie) មិនល្បីល្បាយដោយសារតែគាត់ជាសមាជិកនៅក្នុងពង្សាវតាក្សត្រនោះទេ ប៉ុន្តែដោយសារគាត់ជារូបវិទូ និង ជាគីមីវិទូ ដែលបានធ្វើរបកគំហើញ រេឌីយ៉ូម (Radium) និង ភូលូញ៉ូម (Polonium)។

ផ្ទុយទៅវិញ ភាវៈដ៏ខ្ពង់ខ្ពស់ឧត្តមនៅក្នុងសាកលលោក មានសារៈសំខាន់សម្រាប់យើង ព្រោះទ្រង់គឺជាទ្រង់។ ស្របពេលជាមួយគ្នា អ្វីដែលទ្រង់*ធ្វើ* (ព្រះរាជ្យកិច្ចរបស់ទ្រង់) គឺមានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់យើង។ ព្រះរាជ្យកិច្ចទីមួយរបស់ព្រះជាម្ចាស់ គឺការបង្កើតសាកលលោក (គម្ពីរលោកុប្បត្តិ ជំពូក១ និង ជំពូក២)

តាមរយៈការសម្តែងឫទ្ធានុភាពនៃការបង្កើតរបស់ទ្រង់ ព្រះជាម្ចាស់បានបង្កើតឲ្យមានទាំងសាកលលោកដែលអាចមើលឃើញ និង មិនអាចមើលឃើញ។ ទាំងនេះរួមមានប្រព័ន្ធនៃពិភពលោកដែលមានរូប (ព្រះអាទិត្យ ព្រះច័ន្ទ ដួងតារា ភព និង របស់ជាច្រើនផ្សេងទៀត) និង ភាវៈគ្រប់ជាន់ថ្នាក់រួមទាំងភាវៈជាវិញ្ញាណទាំងអស់ លើកលែងព្រះអង្គផ្ទាល់។ ការបង្កើតនេះ គឺថ្លែងប្រាប់យ៉ាងច្បាស់នៅក្នុងបទគម្ពីរ ដូចដែលយើងបានឃើញស្រេច។

ព្រឹត្តិការណ៍នៅក្នុងព្រះគម្ពីរបានបង្ហាញ សកម្មភាពនៃការបង្កបង្កើតតាមលំដាប់ ដែលនៅពេលបូកបញ្ចូលគ្នាបង្កើតបានទៅជាដំណើររឿងដ៏អស្ចារ្យ នៃការបង្កបង្កើត (គម្ពីរលោកុប្បត្តិ ១និង២ គម្ពីរទំនុកតម្កើង ៣៣:៦) ។ ការពិតនៃការបង្កបង្កើតមានអត្ថន័យសម្រាប់ជីវិតរបស់យើង តាមរបៀបជាច្រើនយ៉ាង៖

១. ការដឹងថាព្រះអាទិករនៃសាកលលោក ទ្រង់គង់នៅតាំងពីមុនអ្វីៗទាំងអស់ផ្សេងទៀត នឹងអាចធ្វើឲ្យយើងស្ញប់ស្ញែងភាពអស្ចារ្យ និង ព្រះតេជៈដ៏អស់កល្បជានិច្ចរបស់ព្រះជាម្ចាស់ និង អាចឲ្យយើងដឹងពីភាពមិនសំខាន់របស់យើង ដោយធៀបជាមួយនឹងទ្រង់។

២. ព្រះអម្ចាស់នៃរបស់សព្វសារពើ ទ្រង់មានសិទ្ធិទទួលបានការថ្វាយបង្គំ និង ការបម្រើដោយការស្តាប់បង្គាប់ ពីរបស់ដែលទ្រង់បានបង្កើត។

៣. នៅក្នុងការបង្កើតពិភពលោក យើងឃើញការបើកបង្ហាញជាទូទៅមួយរបស់ព្រះអាទិករ ដែលតាមរយៈការនេះ ព្រះប្រាជ្ញាញាណ ព្រះឫទ្ធានុភាព និង ការយកព្រះទ័យទុកដាក់ទៅលើស្នាព្រះហស្តរបស់ទ្រង់ ក៏ត្រូវបានបង្ហាញឲ្យឃើញ (គម្ពីររ៉ូម ១:១៨-២០)។

៤. សេចក្តីបង្រៀនរបស់ព្រះគម្ពីរទៅលើការបង្កើតពិភពលោក គឺជាមូលដ្ឋានគ្រឹះនៃជំនឿរបស់យើង ដ្បិតយើងមិនអាចថ្វាយខ្លួនរបស់យើងទៅព្រះណាផ្សេងទៀតដែលមានឫទ្ធានុភាពតិចជាងព្រះអាទិករដែលបានបង្ហាញនៅក្នុងបទគម្ពីរ ដើម្បីទទួលការសង្គ្រោះដ៏អស់កល្បជានិច្ចបានឡើយ។

យើងមិនចាំបាច់ឆ្ងល់ថា*ហេតុអ្វី* បានជាព្រះជាម្ចាស់រចនា និង បង្កើតរបស់គ្រប់យ៉ាងមកនោះទេ។ ទ្រង់ធ្វើយ៉ាងដូច្នេះ ដើម្បីសិរីរុងរឿងរបស់ទ្រង់ (សូមមើលគម្ពីរទំនុកតម្កើង ១៩:១គម្ពីរអេសាយ ៤៣:៧; ៤៨:១១ គម្ពីរវិវរណៈ ៤:១១)។ មនុស្សមានដំណើរជីវិតដោយការស្វែងរកសុភមង្គលទុកជាគោលដៅតែមួយគត់របស់ពួកគេ ប៉ុន្តែសុភមង្គលដ៏ពិតប្រាកដបានមក ពេលណាដែលយើងស្វែងរកការតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់តែមួយគត់ប៉ុណ្ណោះ។ យើងត្រូវបានបង្កើតឡើងដើម្បីបង្ហាញគោលបំណងមួយនោះ ហើយបំណងនោះគឺជាគន្លឹះរបស់យើងឆ្ពោះទៅរកសុភមង្គល។ មិត្តរបស់ខ្ញុំម្នាក់ បានត្អូញត្អែរដាក់ខ្ញុំថា គាត់មិនសប្បាយចិត្តទេ ព្រោះគាត់មិនទាន់អាចធ្វើរឿងអស្ចារ្យសម្រាប់ព្រះជាម្ចាស់។ ខ្ញុំបានសួរទៅកាន់គាត់ថា៖ "តើគោលដៅខ្ពស់បំផុតរបស់អ្នកគឺជាការតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់តាមរយៈអ្វីដែលអ្នកធ្វើមែនទេ? តើអ្នកហ៊ានអនុញ្ញាតឲ្យ*អ្វីៗគ្រប់យ៉ាង* កើតឡើងដើម្បីឲ្យគោលដៅនេះសម្រេចបានដែរ

ឬទេ? មិត្តរបស់ខ្ញុំបានដឹងថាមហិចតារបស់គាត់ ក្នុងការធ្វើអ្វីដែលអស្ចារ្យកន្លងមក ពិតជាគោលដៅសំខាន់នៅក្នុងជីវិតរបស់គាត់មែន។ គាត់គ្រាន់តែកុហកខ្លួនឯង ឲ្យគិតថាគាត់ចង់ធ្វើការទាំងនោះសម្រាប់ព្រះជាម្ចាស់តែប៉ុណ្ណោះ។ ព្រះយេស៊ូបានមានព្រះបន្ទូលថា៖ "ដ្បិតអ្នកណាចង់បានរួចជីវិត អ្នកនោះនឹងបាត់បង់ជីវិតពុំខាន រីឯអ្នកដែលបាត់បង់ជីវិត ព្រោះតែខ្ញុំ និងព្រោះតែដំណឹងល្អ* នឹងបានជីវិតវិញ" (គម្ពីរម៉ាកុស ៨:៣៥) ។ យើងត្រូវបានបង្កើតឡើងមកដើម្បីនាំសិរីរុងរឿងថ្វាយទៅព្រះជាម្ចាស់។

នៅក្នុងក្រុមមនុស្សខ្លះ គេមើលឃើញសាកលលោកនេះថាមានតាំងយូរលុងមកហើយ ជាមួយនឹងប្រវត្តិសាស្ត្រដែលវិលជុំនៅក្នុងវដ្តនៃការបង្កើត ការបំផ្លាញ និង ការបង្កើតឡើងវិញ គ្មានទីបញ្ចប់។ គោលដៅពិតតែមួយសម្រាប់មនុស្សដែលរស់នៅក្នុងក្រុមនេះ គឺដើម្បីរួចផុតពីអត្ថិភាពដែលពេញដោយភាពសោកសៅ។ គំនិតនៅក្នុងព្រះគម្ពីរ អំពីសាកលលោក គឺមានការចាប់ផ្តើម (ការបង្កើតរបស់សព្វសារពើ) មានគោលបំណង (ការសង្គ្រោះមនុស្សជាតិតាមរយៈព្រះយេស៊ូគ្រិស្ត) និង សេចក្តីសន្យាថាមានជីវិតអស់កល្បជានិច្ចនៅក្នុងនគររបស់ព្រះជាម្ចាស់។

ទស្សនៈទាំងពីរនេះ មានបង្ហាញនៅក្នុងគំនូសបម្រួញខាងក្រោម៖




## *លំហាត់អនុវត្តន៍*

១២ ដោយសរសេរនៅក្នុងសៀវភៅរបស់អ្នក ចូរបកស្រាយពីរបៀបដែលទស្សនៈទាំងនេះ ធៀបជាមួយនឹងទស្សនៈដែលយល់ឃើញដោយមនុស្សភាគច្រើនដែលអ្នកស្គាល់។ តើទស្សនៈរបស់ក្រុមមនុស្សនៅក្នុងសង្គមដែលអ្នករស់នៅ ប្រៀបធៀបជាមួយនឹងទស្សនៈនៅក្នុងព្រះគម្ពីរយ៉ាងដូចម្តេច?

ព្រះរាជកិច្ចនៃការបង្កើតរបស់ព្រះជាម្ចាស់ គឺមិនត្រូវបានកំណត់ដោយអ្វីដែលទ្រង់បានធ្វើនៅក្នុងអតីតកាលនោះទេ ។ គម្ពីរយ៉ូហាន ៣:៣ គម្ពីរ២កូរិនថូស ៥:១៧ គម្ពីរកាឡាទី ៦:១៥ និង គម្ពីរទំនុកតម្កើង ៥១:១០ ប្រាប់ថា ព្រះជាម្ចាស់បានបន្សុទ្ធដួងចិត្តអ្នកណាដែលលន់តួអំពើបាបរបស់ពួកគេ ហើយចូលមករកទ្រង់ដោយជំនឿ។ បទគម្ពីរទាំងនេះ ក៏ប្រាប់យើងថា នៅពេលណាដែលមនុស្សបែរទៅរកព្រះជាម្ចាស់ ដើម្បីទទួលការសង្គ្រោះ ពួកគេនឹងបានកើតជាថ្មី ហើយក្លាយជាភាវៈថ្មីមួយទៀត ឬ ជាស្នាព្រះហស្តថ្មីមួយទៀត។ ដូច្នេះព្រះរាជកិច្ចនៃការបង្កើតរបស់ព្រះជាម្ចាស់ រួមមាន ការបង្កើតខាងឯវិញ្ញាណ ដែលធ្វើឡើងនៅពេលមនុស្សម្នាក់ទទួលយកព្រះយេស៊ូគ្រិស្តជាព្រះសង្គ្រោះរបស់ពួកគេ។

## *លំហាត់អនុវត្តន៍*

១៣ ចូរគូសរង្វង់ជុំវិញអក្សរនៅមុខចម្លើយត្រឹមត្រូវ។

ក) ព្រះរាជកិច្ចនៃការបង្កើតរបស់ព្រះជាម្ចាស់ បង្ហាញពីលក្ខណសម្បត្តិរបស់ទ្រង់នៅក្នុងរបៀបទូទៅមួយ ទៅកាន់ភាវៈដែលទ្រង់បានបង្កើត។

ខ) ការបង្កើតពិភពលោក ធ្វើឲ្យយើងដឹងពីភាពអស្ចារ្យ និង ព្រះតេជៈដ៏អស់កល្បជានិច្ចរបស់ព្រះជាម្ចាស់ និង អំពីភាពមិនសំខាន់របស់យើង បើធៀបជាមួយនឹងទ្រង់។

គ) ការបើកសម្តែងរបស់ព្រះជាម្ចាស់នៅក្នុងព្រះរាជកិច្ចនៃការបង្កើតរបស់ទ្រង់ មិនមែនជាការទាមទារឲ្យមានការឆ្លើយតបពីភាវៈដែលទ្រង់បានបង្កើតនោះទេ។

ឃ) ចំណេះដឹងអំពីឫទ្ធានុភាព និង និស្ស័យរបស់ព្រះជាម្ចាស់ ដូចដែលបានបង្ហាញនៅក្នុងការបង្កើតរបស់សព្វសារពើរបស់ទ្រង់ អាចនាំឲ្យយើងថ្វាយសិរីរុងរឿងទៅកាន់ទ្រង់។

ង) ព្រះរាជកិច្ចនៃការបង្កើតរបស់ព្រះជាម្ចាស់ គឺមិនត្រូវបានកំណត់ត្រឹមព្រឹត្តិការណ៍ដែលមានកត់ត្រានៅក្នុងគម្ពីរលោកុប្បត្តិជំពូក១ និងជំពូក២នោះទេ។

# គ. រាជកិច្ចនៃការគ្រងរាជ្យជាព្រះអធិបតីរបស់ព្រះជាម្ចាស់

**វត្ថុបំណងទី៤.** *យកគោលការណ៍ទៅប្រើប្រាស់នៅក្នុងស្ថានភាពជីវិត និង ប្រាប់ពីនិយមន័យនៃការគ្រងរាជ្យជាស្តេចនៃសាកលលោករបស់ព្រះជាម្ចាស់។*

ព្រះអាទិករនៃសាកលលោកដ៏ឧត្តម មានអំណាចគ្រប់គ្រងលើអ្វីទាំងអស់ ដែលទ្រង់បានបង្កើតមក។ តើការនេះមានន័យយ៉ាងដូចម្តេច? ពាក្យថា*ឧត្តម*មានន័យថា "ឋានៈ ឬ អំណាចខ្ពស់បំផុត កម្រិត និង គុណសម្បត្តិ ខ្ពស់បំផុត"។ ព្រះជាម្ចាស់ទ្រង់ខ្ពង់ខ្ពស់ជាងអ្វីៗទាំងអស់នៅក្នុងពិភពលោកនេះ ក្នុងគ្រប់ផ្នែកទាំងអស់។ ពាក្យថា *ព្រះអធិបតី* មានន័យថា "មិនស្ថិតនៅអំណាចគ្រប់គ្រង និង ឫទ្ធានុភាពក្នុងការធ្វើអ្វីៗតាមតែទ្រង់សព្វព្រះហឫទ័យ" ។

ដូច្នេះ អធិបតីភាពរបស់ព្រះជាម្ចាស់ រៀបរាប់អំពីអំណាចគ្រប់គ្រងយ៉ាងឧត្តមរបស់ទ្រង់ នៅលើសាកលលោកទាំងមូល (គម្ពីរ១ធីម៉ូថេ ៦:១៥)។ អធិបតីភាពរបស់ព្រះជាម្ចាស់ គឺត្រូវបានបង្ហាញនៅក្នុងការដឹកនាំរបស់ទ្រង់ទៅលើព្រឹត្តិការណ៍ទាំងអស់នៅក្នុងសាកលលោក ទៅតាមបំណងព្រះហឫទ័យរបស់ទ្រង់ (គម្ពីរអេភេសូ ១:១១)។ បទគម្ពីរបានបង្រៀនយ៉ាងច្បាស់ៗ អំពីអធិបតីភាពរបស់ព្រះជាម្ចាស់ ៖ ១) ក្នុងនាមជាព្រះអាទិកររបស់យើង ទ្រង់មានសិទ្ធិគ្រប់គ្រងលើយើង (គម្ពីរ ១របាក្សត្រ ២៩:១១ គម្ពីរម៉ាថាយ ២០:១៥ គម្ពីរអេសេគាល ១៨:៤) ២) ទ្រង់ធ្វើអ្វីៗគ្រប់បែបយ៉ាង ដែលទ្រង់សព្វព្រះហឫទ័យ (គម្ពីរទំនុកតម្កើង ១១៥:៣ គម្ពីរដានីយ៉ែល ៤:៣៥ ) ៣) អ្វីៗទាំងអស់ដែលទ្រង់ធ្វើគឺសុទ្ធតែមានគោលបំណង ( គម្ពីររ៉ូម ៨:២៨ គម្ពីរអេសាយ ៤៨:១១)។

មានថ្ងៃមួយ ខ្ញុំបានអានកាសែតដែលនិយាយអំពី អំពើឃាតកម្មយ៉ាងសាហាវមួយទៅលើក្មេងស្រីវ័យ៥ឆ្នាំដ៏គួរឲ្យស្រឡាញ់ម្នាក់។ តើរឿងនេះអាចកើតឡើងបានយ៉ាងដូចម្ដេច ប្រសិនបើព្រះជាម្ចាស់ពិតជាព្រះល្អ ពិតជាព្រះអធិបតី និង ជាព្រះដែលមានឫទ្ធានុភាពធ្វើអ្វីដែលទ្រង់សព្វព្រះហឫទ័យមែននោះ? ហេតុអ្វីបានជាទ្រង់អនុញ្ញាតឲ្យមានរឿងបែបនេះកើតឡើងបាន? យើងនឹងស្វែងចម្លើយសម្រាប់សំណួរទាំងនេះ នៅពេលយើងពិចារណាទៅលើផ្នែកផ្សេងៗនៃការគ្រងរាជ្យជាអធិបតីរបស់ព្រះជាម្ចាស់ នៅលើសាកលលោក។ អធិបតីភាពរបស់ព្រះជាម្ចាស់ រួមមាន *ការការពារ* ឬ *ការថែរក្សា* សាកលលោក និង *ឧបការគុណ* ។ ដំបូង យើងនឹងពិចារណាអំពីការការពារ ឬ ការថែរក្សា សាកលលោករបស់ព្រះអង្គ។

## ការការពារ( ការថែរក្សា) សាកលលោក

គ្មានស្ថាបត្យករដ៏ឆ្លាតវៃណាម្នាក់ អាចរចនាផ្ទះដែលមិនទាមទារឲ្យមានការជួសជុលសោះនោះទេ។ គ្មានអ្នកថែសួនណាម្នាក់អាចដាំគ្រាប់ពូជនៃផ្កាដ៏ស្រស់ស្អាត ដោយគ្មានការថែរក្សា ដូចជាលស់មែក ជម្រះស្មៅ និង ស្រោចទឹកនោះទេ។ ព្រះគម្ពីរបានបង្រៀនយើងថា សាកលលោកនេះក៏ត្រូវការការពារ ឬ ការថែរក្សាផងដែរ (គម្ពីរកិច្ចការ ១៧:២៨ គម្ពីរហេប្រឺ ១:៣)។

ព្រះជាម្ចាស់ទ្រង់ថែរក្សា ឬ មើលថែ សាកលោកនេះយ៉ាងសកម្ម។ បទគម្ពីរបានបង្ហាញថា ក្រោយពេលទ្រង់បង្កើតរបស់សព្វសារពើហើយ ព្រះជាម្ចាស់បន្ត សកម្មភាពរបស់ទ្រង់ដោយមើលថែរបស់សព្វសារពើទាំងអស់ (គម្ពីរទំនុកតម្កើង ១០៤)។ របស់ទាំងនេះរួមទាំងមនុស្ស និង សត្វ (គម្ពីរទំនុកតម្កើង ៣៦:៦) និង ការពារអស់អ្នកដែលត្រឹមត្រូវ និង មនុស្សសុចរិត (គម្ពីរសុភាសិត ២:៨)។

លោកសាវ័កប៉ុលបានប្រកាសថា៖ "ដ្បិតយើងមានជីវិត មានចលនា និងមានភាវៈជាមនុស្សដោយសារព្រះអង្គ" (គម្ពីរកិច្ចការ ១៧:២៨) ។ ព្រះជាម្ចាស់មិនអាចជាព្រះអធិបតីបាននោះទេ ប្រសិនបើអ្វីៗដែលមាន ឬ កើតឡើងនៅក្នុងសាកលលោកស្ថិតនៅដាច់ឆ្ងាយពីបំណងព្រះហឫទ័យ និង ឫទ្ធានុភាពរបស់ទ្រង់។ បទគម្ពីរដូចជាគម្ពីរនេហេមា៩:៦ និង គម្ពីរទំនុកតម្កើង ១៤៥:១៤-១៦ បង្រៀនថា ព្រះជាម្ចាស់ទ្រង់ចូលរួមយ៉ាងសកម្ម នៅក្នុងការការពាររបស់សព្វសារពើ។ បទគម្ពីរខ្លះទៀត ប្រកាសថា ព្រះអម្ចាស់ការពារប្រជារាស្ត្ររបស់ទ្រង់ (គម្ពីរទុតិយកថា ១:៣០-៣១ គម្ពីរទំនុកតម្កើង ៣១:២០; ៣៤:១៥,១៧,១៩ គម្ពីរអេសាយ ៤៣:២)។

យើងត្រូវតែដឹងថា ការការពារពីព្រះជាម្ចាស់គឺមានភាពចាំបាច់ណាស់ ព្រោះអ្វីគ្រប់យ៉ាងដែលព្រះជាម្ចាស់បានបង្កើតមក គឺត្រូវពឹងផ្អែកទាំងស្រុងលើទ្រង់ ទាំងការរស់រានមានជីវិត និង ការធ្វើសកម្មភាព។ ភាវៈទាំងអស់គ្មានអំណាចអ្វីដែលអាចបន្តអត្ថិភាពដោយខ្លួនឯងបានឡើយ។ ភាវៈទាំងនោះមានជីវិត និង បន្តមានជីវិតទៅមុខទៀត ដោយព្រោះតែបំណងព្រះហឫទ័យរបស់ព្រះអាទិករ។ ដោយសារតែអំណាចនៃព្រះបន្ទូលរបស់ទ្រង់ ភាវៈទាំងអស់ និង សាកលលោកទាំងមូល ទទួលបានការគាំពារ និង ថែរក្សា (គម្ពីរហេប្រឺ ១:៣)។

នៅពេលរបស់សព្វសារពើ បន្តមានអត្ថិភាពដោយសារការធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ទ្រង់បានប្រទានលក្ខណៈពិសេសៗ ទៅផ្នែកនីមួយៗនៃស្នាព្រះហស្ដរបស់ទ្រង់ ដើម្បីជាប្រយោជន៍ដល់ការថែរក្សារបស់នោះ។ នៅក្នុងពិភពមានរូប ទ្រង់ធ្វើការតាមរយៈលក្ខណៈមានរូបរាង និង ច្បាប់ ដែលពេលខ្លះយើងសំដៅទៅលើ "ច្បាប់ធម្មជាតិ" ។ នៅក្នុងពិភពខាងឯប្រាជ្ញា ទ្រង់ធ្វើការតាមរយៈលក្ខណៈ និង សមត្ថភាពនៃគំនិត ទ្រង់បានប្រទានឲ្យយើងនូវសមត្ថភាពក្នុងការគិត ឆន្ទៈនិងធ្វើការសម្រេចចិត្ត។ ព្រះជាម្ចាស់ធ្វើការតាមរយៈលក្ខណៈទាំងនេះ នៅក្នុងទំនាក់ទំនងជាមួយយើងរាល់គ្នា។ នៅក្នុងការការពារ ពិភពលោក ព្រះជាម្ចាស់មិនរំខានប៉ះពាល់អ្វីដែលទ្រង់បានធ្វើហើយជាមួយនឹងស្នាព្រះហស្ដរបស់ទ្រង់ឡើយ។ ទ្រង់គ្រាន់តែថែរក្សាអ្វីដែលទ្រង់បានបង្កើតមកតែប៉ុណ្ណោះ។

## លំហាត់អនុវត្តន៍

១៤ (ចូរជ្រើសរើសចម្លើយត្រឹមត្រូវ)។ ការថែរក្សារបស់ព្រះជាម្ចាស់ចំពោះស្នាព្រះហស្ដរបស់ទ្រង់មានន័យថា

ក) ទ្រង់មានឫទ្ធានុភាពដែលមានកម្រិតមួយ ដើម្បីផ្លាស់ប្ដូររបស់ណាដែលបានរងការខូចខាត។
ខ) ទ្រង់បានចូលរួមយ៉ាងសកម្មនៅក្នុងការការពាររបស់សព្វសារពើ។
គ) គ្រប់ផ្នែកទាំងអស់នៃស្នាព្រះហស្ដរបស់ទ្រង់មានសមត្ថភាពក្នុងការថែរក្សាខ្លួនឯង។
ឃ) ទ្រង់បានប្រទានលក្ខណៈចាំបាច់ទៅកាន់គ្រប់ផ្នែកនៃស្នាព្រះហស្ដរបស់ទ្រង់ ហើយទ្រង់ធ្វើការតាមរយៈលក្ខណៈទាំងនេះដើម្បីថែទាំរបស់សព្វសារពើ។
ង) ដោយបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ របស់សព្វសារពើនៅក្នុងសាកលលោកនេះបានបន្តនៅមាន។
ច) ទ្រង់ប្រទានការថែទាំ និង ការការពារសម្រាប់ប្រជារាស្ត្ររបស់ព្រះអង្គ។
ឆ) ទ្រង់បានខ្វល់ព្រះទ័យតែពីរឿងការការពារមនុស្សទៀងត្រង់។

## ឧបការគុណ

**វត្ថុបំណងទី៥.** *លើកឧទាហរណ៍អំពីគោលបំណង ធាតុមូលដ្ឋាន និង ឥទ្ធិពលនៃឧបការគុណរបស់ព្រះជាម្ចាស់។*

ផ្នែកមួយទៀតនៃការគ្រងរាជ្យជាព្រះអធិបតីរបស់ព្រះជាម្ចាស់ គឺ *ឧបការគុណរបស់* ព្រះអង្គ។ ទោះបីជាផ្នែកនេះមានទាក់ទងនឹងការការពារ ប៉ុន្តែវាគឺលើសពីនោះទៅទៀត។ ឧបការគុណនេះ ក៏មានន័យសំដៅទៅលើសមត្ថភាពរបស់ព្រះជាម្ចាស់ក្នុងការទតទៅពេលខាងមុខ ការទាយដឹងមុន និង ការរៀបចំផែនការទុកជាមុន។ វាសំដៅទៅក្នុងសមត្ថភាពរបស់ព្រះជាម្ចាស់ក្នុងការបំពេញបំណងព្រះហឫទ័យដែលធំបំផុតរបស់ទ្រង់នៅក្នុងស្នាព្រះហស្ដរបស់ទ្រង់ ដែលជាការកសាងព្រះរាជ្យរបស់ទ្រង់ នៅក្រោមការគ្រប់គ្រងរបស់ព្រះយេស៊ូគ្រិស្ដ។ ការនេះ និយាយអំពីសកម្មភាពរបស់ព្រះជាម្ចាស់ ដែលតាមរយៈសកម្មភាពនោះ ទ្រង់ថែរក្សា ថែទាំ និង គ្រប់គ្រង អ្វីដែលទ្រង់បានបង្កើត។ របៀបដែលទ្រង់អាចធ្វើការ

ទាំងនេះបាន គឺនៅតែជាអាថ៌កំបាំង ប៉ុន្តែមានរឿងមួយចំនួនដែលយើងអាចដឹង អំពីឧបការគុណរបស់ព្រះជាម្ចាស់ដែលទាក់ទងជាមួយយើង៖

១. ព្រះជាម្ចាស់ចូលរួមដោយផ្ទាល់ ទៅក្នុងពិភពលោកដែលទ្រង់បានបង្កើត។

២. ទ្រង់បណ្តាលឲ្យអ្វីៗទាំងអស់នៅក្នុងធម្មជាតិ ធ្វើចលនាតាមព្រះហឫទ័យរបស់ព្រះអង្គ។

៣. ទ្រង់ផ្តល់អំណាច និង បណ្តាលឲ្យមនុស្សមានតួនាទីជា ភ្នាក់ងារដែលមានសីលធម៌ និង ទំនួលខុសត្រូវ ជាមួយនឹងសេរីភាពក្នុងការជ្រើសរើសរវាងត្រូវ និង ខុស។

៤. ប្រសិនបើយើងជ្រើសរើស ទទួលយកការសង្គ្រោះដែលទ្រង់បានប្រទានមក ព្រះជាម្ចាស់នឹងប្រទានឲ្យយើងនូវជីវិតដ៏អស់កល្បជានិច្ច ជាមួយនឹងសេចក្តីអំណរ និង ភាពរុងរឿងគ្រប់ទាំងអស់ដែលព្រះតេជះរបស់ទ្រង់បានប្រទានឲ្យ។

## គោលបំណងនៃឧបការគុណ

មានគោលបំណងជាច្រើន ចំពោះការគ្រប់គ្រងតាមរយៈឧបការគុណរបស់ព្រះជាម្ចាស់ ដែលជាប់ក្នុងទំនាក់ទំនងរបស់ព្រះជាម្ចាស់ជាមួយនឹងស្នាព្រះហស្តរបស់ទ្រង់ ដែលស្រឡាញ់ និង ស្តាប់បង្គាប់ទ្រង់៖

១. *ការគ្រប់គ្រងរបស់ព្រះជាម្ចាស់ គឺត្រូវបានសំគាល់ដោយ ព្រះទ័យទុកដាក់សម្រាប់យើង។*

បទគម្ពីរជាច្រើនបង្ហាញថា *ព្រះជាម្ចាស់ទ្រង់គ្រប់គ្រង ក្នុងបំណងសម្រាប់ភាពរីករាយនៃប្រជារាស្ត្ររបស់ទ្រង់* ។គម្ពីរទំនុកតម្កើង ៨៤:១១ ថ្លែងថា៖ "ព្រះអង្គតែងតែប្រទានសុភមង្គលអោយអស់អ្នកដែលរស់នៅ ដោយគ្មានសៅហ្មង។" បទគម្ពីរផ្សេងទៀតដូចជា គម្ពីរកិច្ចការ១៤:១៧ និង គម្ពីររ៉ូម ៨:២៨ ក៏បានបង្ហាញពីការខ្វល់ព្រះហឫទ័យរបស់ព្រះជាម្ចាស់សម្រាប់ភាពរីករាយ និង សេចក្តីសុខរបស់យើងផងដែរ។

២. *ការគ្រប់គ្រងរបស់ព្រះជាម្ចាស់គឺត្រូវបានសំគាល់ដោយការខ្វល់ព្រះហឫទ័យចំពោះការអភិវឌ្ឍខាងឯគំនិត និង សីលធម៌នៃប្រជារាស្ត្ររបស់ទ្រង់។*

ទំនាក់ទំនងរបស់ព្រះជាម្ចាស់ជាមួយប្រជារាស្ត្ររបស់ទ្រង់ នៅទូទាំងប្រវត្តិសាស្ត្រ មានរួមបញ្ចូលការបង្រៀនពួកគេ ដើម្បីឲ្យពួកគេដឹងថា ១) អ្វីដែលទ្រង់ត្រូវការពីពួកគេ ២) និស្ស័យរបស់ទ្រង់គឺវិសុទ្ធ ៣) អំពើបាបគឺជាការប្រមាថទៅចំពោះព្រះអង្គ និង ៤) ទ្រង់ប្រទានការអត់ទោសបាប និង ការផ្សះផ្សាជាមួយនឹងទ្រង់វិញ។ នៅក្នុងជំនាន់មុន ទ្រង់បានអនុញ្ញាតឲ្យធ្វើរឿងមួយចំនួន ដូចជាការលែងលះប្តីប្រពន្ធ ព្រោះមនុស្សគឺមិនទាន់ដឹងក្តី (គ្មានការលូតលាស់) ។ គម្ពីរម៉ាកុស ១០:៥ បានថែងអំពីការទាំងនេះ ។ ក្រឹត្យវិន័យនៃគម្ពីរសម្ព័ន្ធមេត្រីចាស់ និង ប្រព័ន្ធរដ្ឋាភិបាលរបស់ពួកលេវី គឺជាផ្នែកមួយនៃដំណើរការក្នុងការអភិវឌ្ឍនេះ។ ក្រឹត្យវិន័យ និងប្រព័ន្ធទាំងនេះ បានរៀបចំផ្លូវសម្រាប់ការបើកសំដែងរបស់កូនចៀមនៃព្រះជាម្ចាស់ (ព្រះយេស៊ូ) ដែលដកយកអំពើបាបចេញពីពិភពលោកនេះ។ ឧបការគុណរបស់ព្រះជាម្ចាស់ទាំងអស់ នៅក្នុងការដឹកនាំប្រជារាស្ត្ររបស់ទ្រង់ចូលទៅក្នុងភាពពេញវ័យ ខាងឯវិញ្ញាណ គឺដើម្បីគោលបំណងក្នុងការរៀបចំពួកគេឲ្យក្លាយជាសម្បត្តិពិសេសរបស់ទ្រង់។

៣. *ការគ្រប់គ្រងរបស់ព្រះជាម្ចាស់ មានគោលដៅចម្បង ដែលជាសិរីរុងរឿងរបស់ទ្រង់ផ្ទាល់។* (គម្ពីរអេភេសូ ១:១១-១៤)។

ភាពឥតខ្ចោះរបស់ទ្រង់ទាំងអស់ គឺត្រូវបានបង្ហាញឲ្យឃើញតាមរយៈការគ្រប់គ្រងរបស់ទ្រង់។ នេះមានន័យថាឧបការគុណដ៏វិសុទ្ធរបស់ទ្រង់ បង្ហាញមកកាន់យើងពីគុណសម្បត្តិនៃអង្គទ្រង់។ ឧទាហរណ៍ *សេចក្តីស្រឡាញ់* របស់ទ្រង់ត្រូវបានបង្ហាញឲ្យនៅការផ្គត់ផ្គង់សម្រាប់ភាវៈដែលទ្រង់បានបង្កើត ជាពិសេសនៅក្នុងការផ្តល់ជូនសម្រាប់ការប្រោសលោះពួកគេតាមរយៈព្រះបុត្រារបស់ទ្រង់។ *សេចក្តីពិត* របស់ទ្រង់ ត្រូវបានបង្ហាញទាំងនៅក្នុងច្បាប់ធម្មជាតិ និង នៅក្នុងភាពស្មោះត្រង់របស់ទ្រង់ក្នុងការបំពេញតាមព្រះបន្ទូលសន្យារបស់ទ្រង់។ *ភាពវិសុទ្ធ* និង *ភាពសុចរិត* របស់ទ្រង់ត្រូវបានបង្ហាញនៅក្នុងការស្អប់អំពើបាបរបស់ព្រះអង្គ។ *ឫទ្ធានុភាព* របស់ទ្រង់ត្រូវបានសម្តែងឲ្យឃើញនៅក្នុងកិច្ចការរបស់ទ្រង់នៅក្នុងការបង្កើត ការប្រោសលោះ និង ឧបការគុណរបស់ទ្រង់។ *ព្រះប្រាជ្ញា* ញាណរបស់ទ្រង់ត្រូវបានឃើញនៅក្នុងរបៀបដែលទ្រង់ធ្វើការដើម្បីសម្រេចបំណងព្រះហឫទ័យរបស់ទ្រង់។ នៅពេលយើងស្គាល់ពីភាពអស្ចារ្យនៃព្រះអាទិកររបស់យើង យើងថ្វាយការគោរព និង ការតម្កើងសិរីរុងរឿងទៅកាន់ទ្រង់។

## លំហាត់អនុវត្តន៍

១៥ តើចម្លើយណាមួយនៅខាងក្រោមនេះជានិយមន័យត្រឹមត្រូវនៃពាក្យថា *ឧបការគុណ* ?
ឧបការគុណគឺ

ក) ការការពារ របស់សព្វសារពើ ដែលព្រះជាម្ចាស់បានប្រទានឲ្យគ្រប់ផ្នែកនីមួយៗនៃស្នាព្រះហស្តរបស់ទ្រង់ នូវសមត្ថភាពក្នុងការបំពេញតម្រូវការផ្ទាល់ខ្លួន ដោយគ្មានការពឹងផ្អែកណាមួយពីទ្រង់នោះឡើយ។

ខ) ការគ្រប់គ្រងរបស់ព្រះជាម្ចាស់ ដែលទ្រង់រក្សា ថែទាំ និង ដឹកនាំ ស្នាព្រះហស្តរបស់ទ្រង់ គឺដើម្បីរៀបចំរបស់ទាំងនោះដើម្បីព្រះរាជ្យដ៏អស់កល្បជានិច្ចរបស់ទ្រង់។

១៦ ចូរផ្គូផ្គងបំណងនៃឧបការគុណ (ខាងស្តាំ) ទៅនឹងការរៀបរាប់អំពីបំណងនោះ (ខាងឆ្វេង)។

| | |
|---|---|
| .......ក) ព្រះជាម្ចាស់ធ្វើការនៅក្នុងរបស់សព្វសារពើ ជាមួយនឹងការខ្វល់ព្រះហឫទ័យសម្រាប់ភាពសុខសប្បាយរបស់មនុស្ស។ | ១) សិរីរុងរឿងរបស់ព្រះជាម្ចាស់ |
| ........ខ) ព្រះជាម្ចាស់ប្រទានឲ្យមានការអប់រំទៅកាន់មនុស្ស អំពីអង្គទ្រង់ និង ការទាមទាររបស់ព្រះអង្គ ដើម្បីឲ្យពួកគេបានក្លាយជាសម្បត្តិដ៏ពិសេសរបស់ទ្រង់។ | ២) ការអភិវឌ្ឍផ្នែកគំនិត និង សីលធម៌របស់មនុស្ស |
| .........គ) ការបើកសំដែងរបស់ព្រះជាម្ចាស់ អំពីគុណសម្បត្តិរបស់អង្គទ្រង់ បង្ហាញឲ្យឃើញបំណងមួយនេះ។ | ៣) ភាពរីករាយរបស់មនុស្ស |

## ធាតុផ្សំនៃឧបការគុណ

តើអ្វីខ្លះជាធាតុផ្សំនៃឧបការគុណ? អ្នកប្រាជ្ញខាងឯព្រះគម្ពីរជាច្រើនបានលើកឡើងថា ឧបការគុណរបស់ព្រះជាម្ចាស់មានបីផ្នែក។ ប៉ុន្តែ ពួកគាត់ដឹងថាមានចំណុចដដែលជាន់គ្នាខ្លះៗ និង ដឹងថាផ្នែកទាំងបីនឹងមិនត្រូវចែកដាច់គ្នាបាន នៅក្នុងព្រះរាជកិច្ចរបស់ព្រះជាម្ចាស់នោះទេ។ ធាតុផ្សំទាំងនោះមាន *ការការពារ ការយល់ស្រប* និង *ការគ្រប់គ្រង*។

១. *ការការពារ*

ការបានពិភាក្សាគ្នាអំពីការការពារឬ ការថែរក្សារបស់ព្រះជាម្ចាស់ ទៅចំពោះសាកលលោក ជាផ្នែកមួយនៃការគ្រងរាជ្យជាព្រះអធិបតីរបស់ព្រះអង្គទៅលើរបស់សព្វសារពើរួចមកហើយ។ព្រះជាម្ចាស់ទ្រង់ចូលរួមយ៉ាងសកម្មនៅក្នុងការការពារស្នាព្រះហស្តរបស់ទ្រង់។ អ្វីៗទាំងអស់ដែលព្រះជាម្ចាស់បានបង្កើតគឺសុទ្ធតែផ្អែកទៅលើទ្រង់ ប៉ុន្តែទ្រង់នៅតែប្រទានលក្ខណៈមួយទៅគ្រប់ផ្នែកនីមួយៗនៃការបង្កើតរបស់ទ្រង់ដើម្បីប្រទានការថែរក្សាសម្រាប់ផ្នែកទាំងនោះ។ គម្ពីរលោកុប្បត្តិ ១:២៤-២៥ ចង្អុលបង្ហាញថា ព្រះជាម្ចាស់បានប្រោសប្រទានឲ្យសត្វនីមួយៗ នូវលក្ខណៈធម្មជាតិជាក់លាក់ ដែលមានពិសេសសម្រាប់ពូជសត្វនោះ។ សត្វនីមួយៗ លូតលាស់ អភិវឌ្ឍ ពេញវ័យ និង បន្តពូជដោយយោងទៅតាមប្រភេទរបស់វា។

២. *ការយល់ស្រប*

ពាក្យថា *ការយល់ស្រប* មានន័យថា៖ "ការព្រមព្រៀង ការសហប្រតិបត្តិការណ៍ ឬ ការយល់ព្រម"។ ពាក្យនេះប្រាប់ពីគំនិតដែលថា គ្មានសកម្មភាពទៅលើបញ្ហាណាមួយ ឬ គំនិតណាមួយអាចធ្វើឡើងបានឡើយ បើគ្មានការយល់ព្រមរបស់ព្រះជាម្ចាស់ និង គំនិតដែលថាឫទ្ធានុភាពរបស់ទ្រង់សហការណ៍ជាមួយនឹងអំណាចផ្សេងៗទៀតដែលនៅក្រោមទ្រង់។ នៅក្នុងគម្ពីរកិច្ចការ ១៧:២៨ និង គម្ពីរ១កូរិនថូស ១២:៦ លោកសាវ័កប៉ូលបានបញ្ជាក់ថា បើគ្មានការយល់ស្របពីព្រះជាម្ចាស់ គ្មានកម្លាំងណា ឬ មនុស្សម្នាក់ណាអាចបន្តជីវិត ឬ ធ្វើសកម្មភាពបាននោះទេ។ ដូច្នេះ ឫទ្ធានុភាពរបស់ព្រះជាម្ចាស់មានឥទ្ធិពលយ៉ាងខ្លាំងទៅលើអំណាចរបស់យើង ដោយគ្មានការបំផ្លាញ ឬ ដកហូតសេរីភាពរបស់យើងឡើយ។ យើងបានរក្សា និង ប្រើប្រាស់អំណាចពីធម្មជាតិរបស់យើង ស្របពេលដែលព្រះជាម្ចាស់ការពារគំនិត និង រូបកាយរបស់យើងឲ្យបំពេញតួនាទីពីធម្មជាតិរបស់វា។

ដោយសារព្រះជាម្ចាស់ជាគ្រឹះនៃអត្ថិភាពរបស់យើង យើងមិនអាចនិយាយថាចំណែករបស់យើងស្មើនឹងចំណែករបស់ព្រះជាម្ចាស់បាននោះទេ។ សាជាថ្មីម្តងទៀត យើងឃើញពីអាថ៌កំបាំងយ៉ាងជ្រាលជ្រៅ ៖ ព្រះជាម្ចាស់បានប្រទានអំណាចពីធម្មជាតិមកឲ្យយើង ដែលយើងអាចប្រើប្រាស់សម្រាប់ការល្អ ឬ ការអាក្រក់។ នៅពេលដែលអំណាចពីធម្មជាតិទាំងនេះ ត្រូវបានយកទៅប្រើប្រាស់នៅក្នុងផ្លូវអាក្រក់ យើងនឹងទទួលខុសត្រូវតែម្នាក់ឯងគត់ ដ្បិតព្រះជាម្ចាស់មិនបានបណ្តាយឲ្យយើងធ្វើទង្វើអាក្រក់នោះទេ (គម្ពីរយេរេមា ៤:៤៤ គម្ពីរយ៉ាកុប ១:១៣-១៤)។ ព្រះជាម្ចាស់ *យល់ស្រប* តាមទង្វើយើង តាមរយៈការប្រទានឲ្យយើងនូវអំណាចពីធម្មជាតិ ប៉ុន្តែផ្លូវអាក្រក់នៃអំណាចទាំងនេះ គឺបង្កឡើងដោយយើងខ្លួនឯង។ ឧទាហរណ៍មួយអំពីការយល់ស្រប គឺនៅក្នុងករណីរបស់លោកយ៉ូសែប (គម្ពីរលោកុប្បត្តិ ៤៥:៥; ៥០:២០) ។ នៅត្រង់នេះ យើងឃើញថា នៅពេលដែលបងប្អូនរបស់គាត់បានប្រើប្រាស់អំណាចធម្មជាតិរបស់

ពួកគេដើម្បីធ្វើការអាក្រក់ ព្រះជាម្ចាស់ប្រឆាំងនឹងទង្វើនោះដើម្បីការល្អ។ ទ្រង់ស្រប ឬ អនុញ្ញាត សកម្មភាពរបស់ពួកគេ ប៉ុន្តែទ្រង់ធ្វើការតាមរយៈសកម្មភាពនោះ ដោយយោងទៅតាមបំណងព្រះហឫទ័យរបស់ទ្រង់។

លោកប៉ូលបានមានប្រសាសន៍ថាព្រះជាម្ចាស់ "បានតំរូវយើងទុកជាមុនដូច្នេះ ស្របតាមផែនការរបស់ព្រះអង្គ ដែលសំរេចគ្រប់កិច្ចការទាំងអស់តាមព្រះហឫទ័យរបស់ព្រះអង្គ" (គម្ពីរអេភេសូ ១:១១) និង ថា ព្រះជាម្ចាស់ធ្វើការនៅក្នុងយើង "ធ្វើអោយបងប្អូនមានទាំងបំណង មានទាំងសមត្ថភាពអាចនឹងប្រព្រឹត្តតាមព្រះបំណងដ៏សប្បុរសរបស់ព្រះអង្គ។" (គម្ពីរភីលីព ២:១៣) ។ ទ្រង់ប្រទានឲ្យយើងនូវចំណេះដឹងជ្រៅជ្រះ នៅក្នុងស្ថានភាពជីវិត និង នាំផ្លូវយើងដោយព្រះវិញ្ញាណរបស់ទ្រង់។ ទ្រង់ព្រមានយើងអំពីផលវិបាក នៃភាពបរាជ័យ និង ព្យាយាមយកឈ្នះយើង យ៉ាងទន់ភ្លន់។ ប៉ុន្តែទ្រង់មិនបានចំអកសេរីភាពរបស់យើង ដោយការបង្ខំឲ្យយើងតាមបំណងព្រះហឫទ័យរបស់ព្រះអង្គឡើយ។ នៅក្នុងការសង្គ្រោះ ទ្រង់ចាប់ផ្តើមកិច្ចការដ៏ស្រស់ស្អាតរបស់ទ្រង់ ដោយឈរនៅខាងក្រៅទ្វារនៃដួងចិត្តរបស់យើង ទាំងគោះទ្វារនោះផង ប៉ុន្តែយើងត្រូវបើកទ្វារនោះ (គម្ពីរវិវរណៈ ៣:២០)។ បន្ទាប់មកព្រះវិញ្ញាណដ៏វិសុទ្ធយាងមកគង់នៅក្នុងយើង។ ទ្រង់រក្សាការគ្រប់គ្រងនៅលើជីវិតរបស់យើង ដរាបណាយើងនៅបន្តចុះចូលក្រោមភាពជាព្រះអម្ចាស់របស់ទ្រង់។ ទំនាក់ទំនងរបស់យើងជាមួយទ្រង់ ជាព្រះអម្ចាស់នៃយើង បន្តទៅមុខលើមូលដ្ឋានគ្រឹះនៃក្តីស្រឡាញ់របស់យើងសម្រាប់ទ្រង់ និង ជម្រើសរបស់យើងក្នុងការថ្វាយឲ្យទ្រង់មានការគ្រប់គ្រងមកលើជីវិតរបស់យើង។

៣. *ការគ្រប់គ្រង*

ការនេះសំដៅទៅលើសកម្មភាពនៃការគ្រប់គ្រងរបស់ព្រះជាម្ចាស់ ជាមួយនឹងគោលបំណងដើម្បីសម្រេចបំណងព្រះហឫទ័យរបស់ទ្រង់។ ដូចដែលយើងបានឃើញហើយថា ព្រះជាម្ចាស់គ្រប់គ្រងពិភពលោកដែលមានរូបនេះ តាមមធ្យោបាយនៃច្បាប់ដែលទ្រង់បានបង្កើតឡើង។ ទ្រង់គ្រប់គ្រងមនុស្សតាមរយៈច្បាប់ និង លក្ខណៈនៃគំនិត និងតាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធធ្វើការ។ នៅក្នុងការធ្វើរឿងទាំងនេះ ទ្រង់ប្រើប្រាស់ឥទ្ធិពលគ្រប់ប្រភេទ ដូចជាកាលៈទេសៈ ការជំរុញ ការណែនាំ ការបញ្ចុះបញ្ចូល និង គំរូ។ ទ្រង់ធ្វើការដោយផ្ទាល់តាមរយៈ ការប្រើប្រាស់ព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីជះឥទ្ធិពលទៅលើគំនិតបញ្ញា អារម្មណ៍ និង ឆន្ទៈរបស់យើង។

ព្រះជាម្ចាស់គ្រប់គ្រងតាមរយៈមធ្យោបាយយ៉ាងតិចបួនយ៉ាង។ ការស្វែងយល់ពីមធ្យោបាយទាំងនេះ ជួយឲ្យយើងឃើញទំនាក់ទំនងរវាងបំណងព្រះហឫទ័យដ៏ឧត្តមបំផុតរបស់ព្រះជាម្ចាស់ នៅក្នុងការសម្រេច ផែនការដ៏វិសុទ្ធរបស់ទ្រង់ ជាមួយនឹងឆន្ទៈរបស់យើងនៅក្នុងការធ្វើសកម្មភាពដោយមានសេរីភាព។

ក. ពេលខ្លះព្រះជាម្ចាស់ *មិនធ្វើអ្វីម្យ៉ាង* ដើម្បីរារាំងយើងមិនឲ្យធ្វើអ្វីដែលយើងបានជ្រើសរើសធ្វើឡើយ។ នេះមិនមែនមានន័យថាព្រះជាម្ចាស់ យល់ស្របឲ្យមនុស្សម្នាក់ធ្វើអំពើបាបនោះទេ ប៉ុន្តែទ្រង់ក៏ប្រើប្រាស់ឫទ្ធានុភាពរបស់ទ្រង់ដើម្បីរារាំងការនោះផងដែរ។ ឧទាហរណ៍ អំពីការនេះមាននៅក្នុង គម្ពីរកិច្ចការ ១៤:១៥-១៦ និង គម្ពីរទំនុកតម្កើង ៨១:១២-១៣។

ខ. ពេលខ្លះ ព្រះជាម្ចាស់*រារាំង* មនុស្សពីការធ្វើអំពីបាប ដោយជះឥទ្ធិពលទៅលើពួកគេមិនឲ្យប្រព្រឹត្តិអំពើបាប។ ឧទាហរណ៍មាននៅក្នុងគម្ពីរលោកុប្បត្តិ ២០:៦, ៣១:២៤ និង គម្ពីរហូសេ ២:៦។ អ្នកនិពន្ធបានអធិស្ឋានសម្រាប់ជំនួយបែបនេះ នៅក្នុងគម្ពីរទំនុកតម្កើង ១៩:១៣ ៖ "សូមការពារទូលបង្គំអោយ...........ឥតជាប់ជំពាក់នឹងអំពើបាបដ៏ធ្ងន់នេះទេ។

គ. ពេលខ្លះ ដោយមានការ*ដឹកនាំ* ដ៏វិសុទ្ធ ព្រះជាម្ចាស់បាន *គ្រប់គ្រង* លើទង្វើរបស់មនុស្សអាក្រក់ ដោយប្រើប្រាស់ពួកគេដើម្បីសម្រេចបានលទ្ធផលល្អ។ យើងបានឲ្យឧទាហរណ៍អំពីការនេះ រួចមកហើយនៅក្នុងចំណុចដែលនិយាយអំពីលោកយូសែប។ បងប្អូនរបស់គាត់បានធ្វើអំពើបាប ប៉ុន្តែព្រះជាម្ចាស់បានប្រើប្រាស់ការនោះដើម្បីសម្រេចបាននូវអ្វីម្យ៉ាងដែលល្អ។

ឃ. ចុងក្រោយ ពេលខ្លះព្រះជាម្ចាស់ *បានសម្រេចព្រះទ័យធ្វើការកំណត់អំពើបាប* និង ភាពទុច្ចរិត។ បទគម្ពីរដូចជាគម្ពីរយ៉ូប១:១២ និង ២:៦ បានបញ្ជាក់ថា ព្រះជាម្ចាស់បានដាក់កំណត់ទៅលើសកម្មភាពរបស់សាតាំង។ នៅក្នុងគម្ពីរ១កូរិនថូស ១០:១៣ លោកប៉ូលបានប្រកាសថាព្រះជាម្ចាស់ក៏បានដាក់កំណត់មួយ ទៅលើការល្បងល និង ការល្បួង ដែលគ្រិស្តបរិស័ទត្រូវ អត់ទ្រាំជាមួយ។

ឧបការគុណបានផ្តល់គំនិតឲ្យយើងដឹងថាព្រះជាម្ចាស់គ្រប់គ្រងលើរបស់សព្វសារពើ ដោយក្តីស្រឡាញ់។ សេចក្តីស្រឡាញ់នេះ ត្រូវបានបង្ហាញឲ្យឃើញយ៉ាងច្បាស់បំផុតនៅក្នុងពាក្យរបស់លោកសាវ៉ក ៖ " យើងដឹងទៀតថា អ្វីៗទាំងអស់ផ្សំគ្នាឡើង ដើម្បីអោយអស់អ្នកស្រឡាញ់ព្រះជាម្ចាស់ បានទទួលផលល្អ គឺអ្នកដែលព្រះអង្គបានត្រាស់ហៅមក ស្របតាមគំរោងការរបស់ព្រះអង្គ" (គម្ពីររ៉ូម ៨:២៨)។

## *លំហាត់អនុវត្តន៍*

---

១៧ ចូរផ្គូផ្គងធាតុផ្សំនៃឧបការគុណ (ខាងស្តាំ) ទៅនឹងការរៀបរាប់របស់ធាតុផ្សំ (ខាងឆ្វេង)។

.........ក) ឫទ្ធានុភាពរបស់ព្រះជាម្ចាស់ធ្វើការជាមួយនឹងអំណាចផ្សេងៗដែលនៅក្រោមទ្រង់ ប៉ុន្តែនៅពេលដែលព្រះជាម្ចាស់អនុញ្ញាតឲ្យអំណាចទាំងនោះធ្វើការសម្រេចចិត្តដោយខ្លួនឯង ទ្រង់មិនបានធ្វើឲ្យមានទង្វើអាក្រក់កើតឡើងសោះឡើយ។

.........ខ) ព្រះជាម្ចាស់គ្រប់គ្រងតាមរបៀបមួយដែលនឹងអាចឲ្យសម្រេចបានគំរោងការដ៏វិសុទ្ធរបស់ទ្រង់។ នេះមានន័យថាពេលខ្លះទ្រង់មិនធ្វើអ្វីសោះ ពេលខ្លះទ្រង់រារាំង ពេលខ្លះទៀតទ្រង់គ្រប់គ្រង ហើយពេលខ្លះ ទ្រង់ដាក់កំណត់សកម្មភាពណាដែលធ្វើឡើងមានបំណងអាក្រក់។

១) ការការពារ
២) ការយល់ស្រប
៣) ការគ្រប់គ្រង

.........គ) ព្រះជាម្ចាស់បានប្រទានឲ្យសត្វលោកដែលជារបស់ទ្រង់នូវ
លក្ខណៈធម្មជាតិ តាមរយៈលក្ខណៈទាំង
នេះ ទ្រង់ធ្វើការដើម្បីប្រទានការថែរក្សាសម្រាប់
ពួកគេ អ្វីៗដែលទ្រង់បានបង្កើត មានលក្ខណៈ
ដោយផ្អែកទៅលើទ្រង់ជាដាច់ខាតដើម្បីមានជីវិត
រស់។

## ឥទ្ធិពលនៃឧបការគុណ

តើឧបការគុណមានឥទ្ធិពលទៅលើបទពិសោធន៍ផ្ទាល់ខ្លួនយ៉ាងដូចម្តេច? បទគម្ពីរជាច្រើនបង្ហាញពីការសន្យារបស់ព្រះជាម្ចាស់ ដើម្បីប្រទានពរសម្រាប់មនុស្សសុចរិត (សូមមើលគម្ពីរលេវីវិន័យ ២៦:៣-១៣ គម្ពីរទុតិយកថា ២៨:១-១៤)។ ទ្រង់ប្រទានពរមនុស្សរបស់ទ្រង់។ ព្រះពររបស់ទ្រង់ គឺមានច្រើនលើសជាងការដែលយើងអាចនិយាយបាន។

ប៉ុន្តែមនុស្សសុចរិតតែងតែឆ្ងល់ថា " ហេតុអ្វីបានជាមនុស្សអាក្រក់ក៏ទទួលបានការរីកចម្រើនដែរ? ហេតុអ្វីបានជាពួកគេមិនត្រូវទទួលទោស?" អ្នកនិពន្ធកណ្ឌគម្ពីរទំនុកដំកើងបានឆ្លើយតបថា ១) ការរីកចម្រើនរបស់ពួកគេគឺតែមួយរយៈពេលប៉ុណ្ណោះ ហើយ ២) ព្រះជាម្ចាស់នឹងវិនិច្ឆ័យទោសភាពទុច្ចរិតរបស់ពួកគេនៅថ្ងៃណាមួយ (គម្ពីរទំនុកតម្កើង ៣៧:១៦-២២; ៧៣:១-២៨ ហើយសូមមើលនៅក្នុងគម្ពីរម៉ាឡាគី ៣:១៣-៤:៣)។

ដូច្នេះ នៅពេលមាននរណាម្នាក់សួរអ្នក "ហេតុអ្វីបានជាព្រះជាម្ចាស់មិន បញ្ឈប់អំពីហិង្សាទាំងអស់?" អ្នកអាចឆ្លើយតបទៅវិញប្រកបដោយទំនុកចិត្តថា "សូមចាំមើលពីឈុតចុងក្រោយនៃល្ខោននេះទៅ ។ ព្រះជាម្ចាស់បានចាប់ផ្តើមផែនការរបស់ទ្រង់ក្នុងការលុបបំបាត់ភាពអាត្មានិយម ភាពអស់សង្ឃឹម ការបះបោរ និង ភាពពុករលួយ។ នៅក្នុងផែនការដ៏អស់កល្បជានិច្ចរបស់ទ្រង់ នឹងមានការប្រទានពរ និងការរីកចម្រើន សម្រាប់អស់អ្នកណាដែលស្រឡាញ់ទ្រង់។" នៅក្នុងពេលនេះ ព្រះជាម្ចាស់ពន្យារពេលវិនិច្ឆ័យទោស ដើម្បីផ្តល់ឱកាសម្តងទៀតទៅដល់មនុស្សអាក្រក់ដើម្បីធ្វើការ លន់តួ (គម្ពីររ៉ូម ២:៤ គម្ពីរ២ពេត្រុស ៣:៩)។

សំណួរមួយទៀតដែលគ្រិស្តបរិស័ទតែងតែសួរគឺ "ហេតុអ្វីបានជាអ្នកជឿត្រូវរងការសាកល្បងច្រើនខ្លាំងម្ល៉េះ ប្រសិនបើព្រះជាម្ចាស់មានការគ្រប់គ្រងយ៉ាងពេញលេញទៅលើព្រឹត្តិការណ៍នៅក្នុងជីវិត ពិតមែននោះ?" ព្រះគម្ពីរបានបង្ហាញមូលហេតុជាច្រើនៈ

១. ការអនុញ្ញាតឲ្យមានការល្បងលនេះ គឺដើម្បីការអភិវឌ្ឍខាងវិញ្ញាណរបស់អ្នកជឿ (គម្ពីរទំនុកតម្កើង ៩៤:១២ និងគម្ពីរហេប្រឺ ១២:៥-១៣) ។
២. ការល្បងលប្រហែលជាតំណាងឲ្យការសាកល្បង ការរៀបចំខ្លួនសម្រាប់ឱកាសនៃការបម្រើ (គម្ពីរ ១កូរិនថូស ១៦:៩ គម្ពីរយ៉ាកុប ១:២-១២)។

៣. ការរងទុក្ខវេទនា ក៏នឹងនាំសិរីរុងរឿងថ្វាយទៅព្រះជាម្ចាស់ ប្រសិនបើយើងឆ្លើយតបតាមរបៀបត្រឹមត្រូវ (សូមមើលគម្ពីរ យ៉ូប១,២ និង ៤២)

៤. ការល្បងលគឺជាផ្នែកនៃការត្រាស់ហៅរបស់ព្រះជាម្ចាស់ចំពោះក្រុមជំនុំ (គម្ពីរយ៉ូហាន ១៥:១៨;១៦:៣៣ គម្ពីរកិច្ចការ១៤:២២ គម្ពីរ១ពេត្រុស ៤:១២-១៩)

ដោយសារពេលខ្លះព្រះជាម្ចាស់លូកព្រះហស្តយ៉ាងសកម្ម នៅក្នុងកិច្ចការរបស់មនុស្ស យើងដឹងថាយើងអាចមានតួនាទីយ៉ាងមានប្រសិទ្ធភាពមួយនៅក្នុងជីវិតរបស់អ្នកដទៃ នៅពេលដែលយើងព្ធការអធិស្ឋាន។ លោកម៉ូសេបានទូលអង្វរជាមួយព្រះជាម្ចាស់ ហើយអ៊ីស្រាអែលក៏បានសង្គ្រោះឲ្យផុតពីការបំផ្លិចបំផ្លាញ។ លោកអេលីយ៉ាបានអធិស្ឋាន ហើយរាជវាំងក៏ត្រូវបានគេអុកឡុក។ ទាំងនៅក្នុងគម្ពីរសម្ព័ន្ធមេត្រីចាស់ និង ថ្មី មានឧទាហរណ៍ជាច្រើនពីការចូលអន្តរាគមន៍របស់ព្រះជាម្ចាស់ នៅពេលដែលមនុស្សបានអធិស្ឋាន។ ព្រះជាម្ចាស់បានធ្វើអ្វីម្យ៉ាង ដែលជាការឆ្លើយតបទៅនឹងការអធិស្ឋានរបស់មនុស្សដោយផ្ទាល់។ ទ្រង់ធ្វើកិច្ចការខ្លះទៀត ដោយគ្មាននរណាម្នាក់អធិស្ឋានសូមទ្រង់ដែរ។ ពេលខ្លះទ្រង់ធ្វើរឿងដែលហាក់បីដូចជាផ្ទុយទៅនឹងអ្វីដែលយើងអធិស្ឋានទូលសូម ដោយព្រោះអធិបតីភាពរបស់ទ្រង់ ទ្រង់ធ្វើការដើម្បីផលល្អបំផុតរបស់យើង។ លោក ហិនរី ស៊ី ថៃសិន(Henry C. Thiessen (1979))[1] បាននិយាយសរុបការនេះ ដូចខាងក្រោមនេះ៖

> ប្រសិនបើយើងមិនអធិស្ឋានសម្រាប់រឿងដែលយើងអាចទទួលបានដោយការអធិស្ឋាននោះទេ យើងនឹងមិនទទួលបានវាឡើយ។ ប្រសិនបើទ្រង់សព្វព្រះហឫទ័យឲ្យរឿងអ្វីមួយកើតឡើងដោយគ្មាននរណាម្នាក់អធិស្ឋានសម្រាប់រឿងនោះ ទ្រង់នឹងធ្វើរឿងទាំងនោះដោយមិនចាំបាច់មាននរណាម្នាក់អធិស្ឋានទូលសូមឡើយ។ ប្រសិនបើយើងអធិស្ឋានសម្រាប់រឿងដែលផ្ទុយទៅនឹងបំណងព្រះហឫទ័យរបស់ទ្រង់ ទ្រង់នឹងបដិសេធមិនប្រទានឲ្យយើងឡើយ។ ដូច្នេះ មានភាពចុះសម្រុងគ្នាដ៏ល្អឥតខ្ចោះមួយ រវាងបំណងព្រះហឫទ័យរបស់ទ្រង់ និង ឧបការគុណ និង ឆន្ទះសេរីរបស់មនុស្ស ។ (១២៩)

ដូច្នេះ យើងបានឃើញហើយថា ពេលខ្លះ គ្រិស្តបរិស័ទក៏បានរងទុក្ខដោយសារតែការរស់នៅក្នុងលោកីយ៍ដ៏អាក្រក់នេះផងដែរ។ ព្រះជាម្ចាស់ ដែលគង់នៅគ្រប់គ្រង មិនបានរារាំងមនុស្សពីការធ្វើអំពើអាក្រក់គ្រប់ពេលនោះទេ។ ទាំងគ្រិស្តបរិស័ទ និង អ្នកមិនមែនគ្រិស្តបរិស័ទ អាចនឹងរងទុក្ខ ជាលទ្ធផលដែលមកពីឧបទ្ទវហេតុ ឬ ការឆ្វេសប្រហែសដូចគ្នា។ ព្រះជាម្ចាស់មិនលូកព្រះហស្តរបស់ទ្រង់មកក្នុងច្បាប់ធម្មជាតិធម្មតា ឬ ជម្រើសនៃឆន្ទៈផ្ទាល់ខ្លួនរបស់យើងគ្រប់ពេលនោះទេ។ មនុស្សគ្រប់រូបរស់នៅក្នុងពិភពលោក មនុស្សម្នាក់ៗជាអ្នករងគ្រោះដោយសារឧបទ្ទវហេតុ និង ពេលខ្លះដល់ថ្នាក់ស្លាប់ទៀតផង។ គោលដៅរបស់យើង គឺមិនមែនដើម្បីបំពេញតាមគំនិតរបស់យើងទាក់ទងនឹងជីវិតនោះឡើយ ប៉ុន្តែគឺដើម្បីរស់នៅក្នុងរបៀបមួយដែលនឹងនាំសិរីរុងរឿងថ្វាយទៅព្រះជាម្ចាស់។ សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់សម្រាប់យើង មិនដែលផ្លាស់ប្រែ ហើយទ្រង់បានមានព្រះបន្ទូលសន្យាថា ប្រសិនបើយើងស្រឡាញ់ទ្រង់ ទ្រង់នឹងធ្វើការសម្រាប់ផលល្អរបស់យើង នៅក្នុងគ្រប់ការទាំងអស់។ ជាមួយនឹងចំណេះដឹងនេះ យើងអាចទុកចិត្តដោយខ្លួនឯង ទៅលើព្រះជាម្ចាស់ដ៏ជាក្សត្ររបស់យើងរាល់គ្នា ដោយជឿថាហេតុផលសម្រាប់កាលៈទេ

សៈទាំងអស់ ដែលទ្រង់នាំមក ដែលទ្រង់អនុញ្ញាត ដែលទ្រង់កំណត់ ឬ រារាំង នឹងបានបង្ហាញជាក់ច្បាស់មកកាន់យើង នៅថ្ងៃណាមួយ ដូចដែលទ្រង់បានឈ្វេងយល់អំពីការទាំងនោះដែរ។

## លំហាត់អនុវត្តន៍

---

១៨ ដោយប្រើពាក្យរបស់អ្នកផ្ទាល់ ចូរឆ្លើយសំណួរដែលបានលើកឡើងនៅចំណុចចាប់ផ្តើមនៃផ្នែកនេះ អំពីការគ្រប់គ្រងជាអធិបតី៖ "តើព្រះជាម្ចាស់អាចបណ្តាលឲ្យមានអំពីឃាតកម្មទៅលើក្មេងតូចដែលគ្មានកំហុសម្នាក់ ទៅបានយ៉ាងដូចម្តេច?" ចូរសរសេរចម្លើយក្នុងសៀវភៅកតើត្រារបស់អ្នក។

១៩ ចូរអានបទគម្ពីរខាងក្រោម ហើយសរសេរលេខ ១ នៅក្នុងចន្លោះបន្ទាត់ ប្រសិនបើប្រយោគនោះគឺជាឧទាហរណ៍មួយអំពីឧបការគុណរបស់ព្រះជាម្ចាស់នៅក្នុងការទាក់ទងជាមួយមនុស្ស។ ចូរសរសេរលេខ ២ ប្រសិនបើប្រយោគនោះជាឧទាហរណ៍អំពីជម្រើសផ្ទាល់ខ្លួនរបស់មនុស្ស ដែលគ្មានការលូកព្រះហស្តពីព្រះជាម្ចាស់នោះទេ។

.........ក) គម្ពីរចៅហ្វាយ ១៥:១៦-១៩៖ ការប្រទានទឹកសម្រាប់លោកសាំសុនដែលកំពុងតែហត់។

.........ខ) គម្ពីរកិច្ចការ ២៤:២៤-២៦ ៖ លោកភេលិចបានពន្យាពេលធ្វើការសម្រេចចិត្តទទួលដំណឹងល្អ។

..........គ) គម្ពីរដានីយ៉ែល២:១០-២៣ ៖ ការបើកសំដែងទៅកាន់លោកដានីយ៉ែល

..........ឃ) គម្ពីរលោកុប្បត្តិ ២២:១៣ ៖ ចៀមឈ្មោលមួយជាប់ស្នែងនឹងគុម្ពោតឈើ។

..........ង) គម្ពីរចៅហ្វាយ ១១:៣០-៣៦ ៖ លោកយែបថាបានធ្វើការសន្យាយ៉ាងល្ងង់ខ្លៅមួយទៅកាន់ព្រះជាម្ចាស់។

២០ ចូរបកស្រាយពីឥទ្ធិពលនៃការគ្រប់គ្រងជាអធិបតី និង តាមបែបឧបការគុណរបស់ព្រះជាម្ចាស់ នៅក្នុងកាលៈទេសៈនីមួយៗខាងក្រោមនេះ ។ ចូរឆ្លើយចម្លើយរបស់អ្នកដោយផ្អែកលើគោលការណ៍ដែលបានបង្រៀននៅក្នុងមេរៀននេះ។ ចូរសរសេរចម្លើយក្នុងសៀវភៅកត់ត្រារបស់អ្នក។

ក) លោកចន ធ្លាប់ជាអ្នកបម្រើម្នាក់នៅក្នុងសហគមន៍ដែលពេញដោយក្រុមជនពាលមួយ។ ជាលទ្ធផលដែលបានមកពីរបស់លោក មានយុវជនប្រុសស្រីជាច្រើននាក់ដែលរស់នៅតាមដងផ្លូវ  បានស្គាល់ព្រះគ្រិស្ត។

ខ) លោករ៉ូប៊ីត (Robert) បានហៀបនឹងស្លាប់ ដោយសារជំងឺមហារីក ប៉ុន្តែតាមរយៈសេចក្តីអធិស្ឋានរបស់មិត្តភក្តិរបស់លោក លោកបានជាសះស្បើយយ៉ាងអស្ចារ្យ។

គ) លោកចេម បានឡើងលើភ្នំដ៏មានគ្រោះថ្នាក់មួយ ជាមួយនឹងមិត្តរបស់លោក ពេលនោះលោកបានដួល ហើយជើងរបស់លោកក៏បានបាក់។

ឃ) នាងស៊ីម៉ូន ត្រូវបានគេស្ទាក់វាយយ៉ាងដំណំ នៅពេលនាងដើរពីព្រះវិហារទៅផ្ទះរបស់នាង ។ តាមរយៈបទពិសោធន៍មួយនេះ នាងក៏បង្កើនការខិតខំប្រឹងដើម្បីនាំមនុស្សមកឯព្រះគ្រិស្ត។

ង) រេម៉ន (Raymond) គឺជាក្មេងដែលមានអំណាយទានម្នាក់ ដែលបានរត់ចេញពីផ្លូវមុខភោជនីដ្ឋាន ចូលទៅក្នុងផ្លូវរបស់ឡានដែលកំពុងតែមានល្បឿនលឿន ហើយក៏ត្រូវឡានបុកស្លាប់ទៅ។

ច) ហេនរី (Henry) រស់នៅដោយខ្វល់តែពីខ្លួនឯង និង មានកេរ្តិ៍ឈ្មោះមិនល្អនៅក្នុង ការព្រមព្រៀងធ្វើជំនួញ ប៉ុន្តែគាត់ហាក់បីដូចជារីកចម្រើននៅក្នុងគ្រប់អ្វីៗដែលគាត់បានធ្វើ។

ឆ) ឡានរបស់បេសកជនម្នាក់ បានបែកកង់នៅតាមផ្លូវទៅចំណតយន្តហោះ ហើយគាត់ក៏បានខកជើងហោះហើររបស់គាត់។ ក្រោយមកគាត់បានដឹងថា យន្តហោះនោះបានធ្លាក់ ហើយមនុស្សគ្រប់គ្នានៅលើយន្តហោះនោះបានបាត់បង់ជីវិតទាំងអស់។

# ការប្រឡងផ្ទាល់ខ្លួន

**ត្រូវ/ខុស។** ចូរសរសេរ ត នៅខាងមុខប្រយោគណាដែលត្រឹមត្រូវ និង សរសេរអក្សរ ខ នៅខាងមុខប្រយោគណាដែលមិនត្រឹមត្រូវ។

.........១ ភាពវិសុទ្ធ គឺជាលក្ខណសម្បត្តិរបស់ព្រះជាម្ចាស់ដែលបង្ហាញឲ្យឃើញពីភាពឥតខ្ចោះទាំងអស់របស់ទ្រង់។

........២ ដោយសារតែព្រះជាម្ចាស់គឺ គ្មានទីបំផុត ហើយមនុស្សគឺពេញដោយបាប ទំនាក់ទំនងរវាងទ្រង់នឹងមនុស្ស គឺគ្មានភាពស្និទ្ធស្នាលនោះទេ។

........៣ បើទោះបីភាពវិសុទ្ធរបស់ព្រះជាម្ចាស់ ទាមទារឲ្យមានការកាត់ផ្ដាច់ពីអ្វីដែលមានបាប ទ្រង់នៅតែមានសេចក្ដីមេត្តាករុណា និង សេចក្ដីស្រឡាញ់ដែលបង្កើតបានជាផ្លូវសម្រាប់បញ្ចប់ការកាត់ផ្ដាច់នេះ ដោយប្រទានឲ្យមានការបូជាមួយ។

.........៤ សេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ ត្រូវបានបង្ហាញឲ្យឃើញច្បាស់បំផុត តាមរយៈអ្វីដែលទ្រង់មានព្រះបន្ទូល។

.........៥ តម្លៃនៃក្ដីស្រឡាញ់ គឺសរបញ្ជាក់តាមរយៈអ្វីដែលមនុស្សម្នាក់ធ្វើ ដែលនោះមានន័យថាទង្វើរបស់មនុស្សម្នាក់ បង្ហាញពីក្ដីស្រឡាញ់របស់គេ។

.........៦ ប្រសិនបើមនុស្សពិតជាស្រឡាញ់ព្រះជាម្ចាស់ពិតមែន ពួកគេនឹងបង្ហាញក្ដីស្រឡាញ់នោះតាមរយៈការស្ដាប់បង្គាប់របស់ពួកគេ។

..........៧ ការបង្កើតសាកលលោកដែលជា កិច្ចការរបស់ព្រះជាម្ចាស់ គឺមានសារៈសំខាន់តែនៅពេលណាដែលវា បង្ហាញពីព្រះតេជះ នៃឫទ្ធានុភាពរបស់ព្រះជាម្ចាស់។ ការនេះមិនទាមទារឲ្យមានការឆ្លើយតបអ្វីនៅក្នុងស្នាព្រះហស្តរបស់ទ្រង់ឡើយ។

.........៨ ការគ្រប់គ្រងជាអធិបតីរបស់ព្រះជាម្ចាស់ មានន័យថាទ្រង់មិនស្ថិតនៅក្រោមការគ្រប់គ្រងដែលមកពីខាងក្រៅណាមួយ ហើយមានន័យថាទ្រង់អាចធ្វើអ្វីៗគ្រប់យ៉ាងដែលទ្រង់សព្វព្រះហឫទ័យ។

..........៩ នៅពេលដែលយើងនិយាយដល់ការដែលព្រះជាម្ចាស់ថែរក្សាសាកលលោក យើងយល់ថាទ្រង់ គឺកំពុងការពារយ៉ាងសកម្ម នូវអ្វីដែលទ្រង់បានបង្កើត។

.........១០ ឧបការគុណសំដៅទៅលើសមត្ថភាពរបស់ព្រះជាម្ចាស់ ក្នុងការទតឃើញជាមុននូវអ្វីៗគ្រប់យ៉ាង និង ក្នុងការដឹកនាំភាវៈដែលទ្រង់បានបង្កើតឆ្ពោះទៅចុងបញ្ចប់ដែលទ្រង់បានកំណត់សម្រាប់ភាវៈទាំងនោះ ដែលនោះគឺជាការបង្កើតនគរមួយនៅក្រោមព្រះយេស៊ូគ្រិស្ត។

.........១១ ការគ្រប់គ្រងរបស់ព្រះជាម្ចាស់រាប់បញ្ចូលគំនិតដែលថា ពេលខ្លះទ្រង់បានដាក់កំណត់ទៅលើអំពើបាប និង ភាពទុច្ចរិត និង ទៅលើការល្បួងលដែលគ្រិស្តបរិស័ទត្រូវរង។

........១២ ស្របពេលដែលការអធិស្ឋានគឺជាសកម្មភាពដែលនឹងនាំយើងឲ្យកាន់តែជិតព្រះជាម្ចាស់ ការអធិស្ឋានមិនអាចមានឥទ្ធិពលទៅលើសកម្មភាពជាអធិបតីរបស់ទ្រង់បានឡើយ។

..........១៣ ស្របពេលដែលព្រះជាម្ចាស់បានបង្កើតច្បាប់ធម្មជាតិ និង ប្រទានឲ្យមនុស្សនូវសេរីភាពនៃការជ្រើសរើស ទ្រង់បានធ្វើការតាមរយៈមធ្យោបាយនេះដើម្បីនាំឲ្យបំណងព្រះហឫទ័យរបស់ទ្រង់បានសម្រេច។

..........១៤ ឧបការគុណរបស់ព្រះជាម្ចាស់ រាប់បញ្ចូល គោលការណ៍ដែលថាគ្រិស្តបរិស័ទត្រូវតែរងទុក្ខនៅក្នុងពិភពលោកនេះ នៅពេលណាដែលមនុស្សមានបាបអាចរំពឹកទុកថាគេនឹងបានរីកចម្រើន។

# ចម្លើយសម្រាប់លំហាត់អនុវត្តន៍

១០ នៅក្នុងបទគម្ពីរទាំងនេះ ព្រះយេស៊ូបានបង្គាប់ឲ្យពួកសាវ័ករបស់ទ្រង់ នាំដំណឹងអំពីសេចក្ដីស្រឡាញ់ និង ការសង្គ្រោះរបស់ព្រះជាម្ចាស់ ទៅកាន់មនុស្សគ្រប់គ្នា ។ ព្រះជាម្ចាស់បានជ្រើសរើសប្រើប្រាស់យើងដើម្បីប្រាប់អ្នកដទៃអំពីក្ដីស្រឡាញ់របស់ទ្រង់។

១ ក) វិសុទ្ធ

ខ) បែកចេញ

គ) អំពីបាបអាក្រក់យ៉ាងណា

១១ ខ) បង្ហាញពីសេចក្ដីល្អ សេចក្ដីមេត្តាករុណា ការអត់ធ្មត់ និង ព្រះគុណ នៅក្នុងទំនាក់ទំនងសម្ព័ន្ធភាពរបស់ទ្រង់ជាមួយមនុស្ស និង សេចក្ដីស្រឡាញ់នេះ បានស្ដែងឡើងនៅតាមរបៀបជាក់ស្ដែងមួយ ដូចជាអត់ទោសបាប។

២ គ) ព្រះសង្គ្រោះរបស់យើងគឺព្រះយេស៊ូគ្រិស្ដ។

១២ ចម្លើយរបស់អ្នក។ នៅក្នុងក្រុមមនុស្សជាច្រើន មានភាពមិនប្រាកដប្រជាជាច្រើនអំពីការបង្កើតសាកលលោក អត្ថន័យនៃជីវិត សេចក្ដីស្លាប់ និង ការវិនិច្ឆ័យទោស។ គ្មានទស្សនៈណាផ្សេងទៀតដែលមានហេតុផលសមរម្យ និង គួរឲ្យគាប់ចិត្តដូចជាទស្សនៈដែលមាននៅក្នុងព្រះគម្ពីរឡើយ។

៣ ចម្លើយរបស់អ្នកគួរតែស្រដៀងនឹងចម្លើយនេះ៖ ទ្រង់តម្រូវឲ្យខ្ញុំបានវិសុទ្ធ។ ទ្រង់សព្វព្រះហឫទ័យឲ្យខ្ញុំចែករំលែកភាពវិសុទ្ធរបស់ទ្រង់។

១៣ ក) ត្រូវ

ខ) ត្រូវ

គ) ខុស

ឃ) ត្រូវ

ង) ខុស (ព្រះរាជកិច្ចនៃការបង្កើត របស់ទ្រង់បន្តក្រោមទម្រង់នៃការបង្កើតខាងឯវិញ្ញាណដែលធ្វើឡើងនៅពេលមនុស្សម្នាក់ទទួលព្រះយេស៊ូជាព្រះសង្គ្រោះ)។

៤ យើងគួរតែឆ្លើយយ៉ាងដូច្នេះថា៖ "សាសន៍សាម៉ារី" ព្រោះគាត់បានបង្ហាញពីការធ្វើអ្វីដែលត្រឹមត្រូវ។ គាត់បានយកគោលការណ៍ដែលគាត់ប្រកាន់ខ្ជាប់ ទៅប្រើប្រាស់នៅក្នុងជីវិត។

១៤ ខ) ទ្រង់បានចូលរួមយ៉ាងសកម្មនៅក្នុងការការពាររបស់សព្វសារពើ។

ឃ) ទ្រង់បានប្រទានលក្ខណៈចាំបាច់ទៅកាន់គ្រប់ផ្នែកនៃស្នាព្រះហស្ដរបស់ទ្រង់ ហើយទ្រង់ធ្វើការតាមរយៈលក្ខណៈទាំងនេះដើម្បីថែទាំរបស់សព្វសារពើ។

ង) ដោយបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ របស់សព្វសារពើនៅក្នុងសាកលលោកនេះបានកើតមានឡើង។

ច) ទ្រង់ប្រទានការថែទាំ និង ការការពារសម្រាប់ប្រជារាស្ដ្ររបស់ព្រះអង្គ។

៥ ខ) មានយុត្តិធម៌នៅក្នុងការទាមទាររបស់យើង ឲ្យរង្វាន់ពួកគេនៅពេលពួកគេស្ដាប់បង្គាប់ ហើយដាក់ទោសពួកគេនៅពេលពួកគេមិនស្ដាប់បង្គាប់។

១៥ ខ) ការគ្រប់គ្រងរបស់ព្រះជាម្ចាស់ ដែលទ្រង់រក្សា ថែទាំ និង ដឹកនាំ ស្នាព្រះហស្តរបស់ទ្រង់ គឺដើម្បីរៀបចំរបស់ទាំងនោះដើម្បីព្រះរាជ្យដ៏អស់កល្បជានិច្ចរបស់ទ្រង់។

៦ ក), គ), ង) និង ច) ជាចម្លើយត្រឹមត្រូវ។

១៦ ក) ៣) ភាពរីករាយរបស់មនុស្ស
 ខ) ២) ការអភិវឌ្ឍផ្នែកគំនិត និង សីលធម៌របស់មនុស្ស
 គ) ១) សិរីរុងរឿងរបស់ព្រះជាម្ចាស់

៧ សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ត្រូវបានបង្ហាញតាមរយៈការប្រទានអ្វីម្យ៉ាង ទៅកាន់មនុស្សរបស់ទ្រង់។

១៧ ក) ២) ការយល់ស្រប
 ខ) ៣) ការគ្រប់គ្រង
 គ) ១) ការការពារ

១៨ ចម្លើយរបស់អ្នក។ ខ្ញុំចង់ចង្អាញប្រាប់ថា ព្រះជាម្ចាស់បានប្រទានឲ្យយើងនូវសេរីភាពក្នុងការសម្រេចចិត្ត ដូច្នេះ យើងអាចជ្រើសរើសធ្វើអំពើបាបបានប្រសិនបើយើងចង់។ នៅពេលដែលមានការនេះកើតឡើង មនុស្សគ្មានកំហុសក៏ត្រូវរងទុក្ខដូចជាមនុស្សទុច្ចរិតដែរ។ ព្រះគម្ពីរប្រាប់យើងថា នៅពេលណាមួយ មនុស្សទុច្ចរិតនឹងទទួលការកាត់ទោស និង ការផ្តន្ទាទោសពីព្រះជាម្ចាស់ ដោយសារតែអំពើអាក្រក់ដែលពួកគេបានធ្វើ។

៨ យើងបង្ហាញក្តីស្រឡាញ់របស់យើង សម្រាប់ព្រះជាម្ចាស់ តាមរយៈការស្តាប់បង្គាប់របស់យើងទៅចំពោះទ្រង់ និង ក្តីស្រឡាញ់របស់យើងសម្រាប់មនុស្សដទៃទៀតដែរ។ (យើងអាចឃើញយ៉ាងច្បាស់នៅត្រង់នេះ ថា ក្តីស្រឡាញ់គឺជាកម្លាំងដ៏សកម្មមួយ)។

១៩ ក) ១) ឧបការគុណរបស់ព្រះជាម្ចាស់
 ខ) ២) ការជ្រើសរើសផ្ទាល់ខ្លួនរបស់មនុស្ស
 គ) ១) ឧបការគុណរបស់ព្រះជាម្ចាស់
 ឃ) ១) ឧបការគុណរបស់ព្រះជាម្ចាស់
 ង) ២) ការជ្រើសរើសផ្ទាល់ខ្លួនរបស់មនុស្ស

៩ ខ១៖ ព្រះប្រាជ្ញាញាណ និង សព្វានុភាព (ធម្មជាតិ) និង សេចក្តីស្រឡាញ់ (សីលធម៌)
 ខ២៖ សព្វានុភាព និង សព្វជ្ញភាព(សព្វត្ថិភាព) (ធម្មជាតិ) និង សេចក្តីស្រឡាញ់ (សីលធម៌)
 ខ៣៖ ភាពវិសុទ្ធ (សីលធម៌)
 ខ៤៖ សេចក្តីស្រឡាញ់ (សីលធម៌)

២០ ឧទាហរណ៍ ក) ឆ្លុះបញ្ចាំងឲ្យឃើញគោលការណ៍ពីរយ៉ាង៖ ការរងទុក្ខអាចជាលទ្ធផលបានមកពីការរស់នៅសម្រាប់ព្រះជាម្ចាស់ នៅក្នុងលោកីយ៍ដ៏អាក្រក់ ពេលខ្លះព្រះជាម្ចាស់ប្រើប្រាស់សកម្មភាពរបស់មនុស្សអាក្រក់ដើម្បីសម្រេចបាននូវលទ្ធផលល្អមួយ។ ឧទាហរណ៍ ខ) គួសបង្ហាញថា ព្រះជាម្ចាស់ធ្វើអ្វីម្យ៉ាង ជាការឆ្លើយតបផ្ទាល់ទៅនឹងការអធិស្ឋាន និង បំណងព្រះហឫទ័យរបស់ទ្រង់គឺដើម្បីនាំសិរីរុងរឿងមកឯទ្រង់។ ឧទាហរណ៍ គ) និង ង) បង្ហាញថាមនុស្សគ្រប់គ្នា គឺជាអ្នករងឥទ្ធិពលពីច្បាប់ធម្មជាតិ និង គ្រោះថ្នាក់ដែលមាននៅក្នុងជីវិត។ ឧទាហរណ៍ ឃ) គួសបង្ហាញថាពេលខ្លះការល្បងល រៀបចំមនុស្សម្នាក់ដើម្បីការបម្រើដ៏អស្ចារ្យមួយដល់ព្រះជាម្ចាស់ និង អាចនាំសិរីរុងរឿងទៅឲ្យទ្រង់។ ឧទាហរណ៍ ច) បង្ហាញថា សូម្បីតែអ្នកដែលមិនមែនជាគ្រិស្តបរិស័ទ ក៏អាចទទួលផលប្រយោជន៍ពីព្រះគុណរបស់ព្រះជាម្ចាស់ដែរ។ ប៉ុន្តែប្រសិនបើលោកហេនរី (Henry) មិនថ្វាយជីវិតរបស់គាត់ទៅព្រះជាម្ចាស់ទេនោះ គាត់នឹងត្រូវរស់នៅដាច់ពីព្រះជាម្ចាស់ជារៀងរហូត ហើយគាត់នឹងត្រូវបានវិនិច្ឆ័យទោស ដោយសារទង្វើអាក្រក់របស់គាត់។ ឧទាហរណ៍ ឆ) គួសបង្ហាញថា ពេលខ្លះនៅពេលដែលផែនការរបស់យើងហាក់បីដូចជាមិនអាចសម្រេចបាន ព្រះជាម្ចាស់កំពុងធ្វើការនៅក្នុងកាលៈទេសៈនោះសម្រាប់ផលល្អរបស់យើង។